

# UCB

## ២០១៨

## របាយការណ៍
## ហិរញ្ញវត្ថុ
## ប្រចាំឆ្នាំ

# UCB

## ធនាគារ សហពាណិជ្ជ កអ.

របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់កាលបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨



# មាតិកា


១. សារពីគណៈគ្រប់គ្រង ទំព័រ ៣

២. ប្រវត្តិរបស់ធនាគារ សហពាណិជ្ជ កអ. ទំព័រ ៥

៣. ទិដ្ឋភាពទូទៅនៃអាជីវកម្ម ទំព័រ ៧

៤. សកម្មភាព និង ការឧបត្ថម្ភ ទំព័រ ១៣

៥. អភិបាលកិច្ចសាជីវកម្ម ទំព័រ ១៥

៦. របាយការណ៍ក្រុមប្រឹក្សាភិបាល ទំព័រ ១៨

៧. របាយការណ៍សវនករឯករាជ្យ ទំព័រ ២៤

៨. របាយការណ៍ហិរញ្ញវត្ថុ ទំព័រ ២៨

៩. សេវាកម្ម និង ផលិតផល ទំព័រ ១១៤

១០. ព័ត៌មានទំនាក់ទំនង ទំព័រ១១៥

# ១. សារពីគណៈគ្រប់គ្រង

ក្នុងឆ្នាំ ២០១៨ ធនាគារ សហាពាណិជ្ជ ក.អ បានទទួលជោគជ័យថ្មីមួយ។ ក្នុងកំឡុងឆ្នាំនេះផងដែរ ធនាគារបានបោះជំហានទៅមុខ ក្នុងការសម្រេចបានគោលដៅធំៗចំនួនបី គឺ ការបង្កើនទំនាក់ទំនងអតិថិជន ការកើនឡើងនូវគុណភាពទ្រព្យសកម្ម និងស្ថិរភាពប្រាក់ចំណេញ។ ធនាគារ សហាពាណិជ្ជ ក.អ បានប្តេជ្ញាក្នុងការក្លាយខ្លួនជាធនាគារបរទេសដ៏ល្អដាច់គេមួយក្នុងប្រទេសកម្ពុជា និងបន្តការអភិវឌ្ឍន៍យូរអង្វែងនៅក្នុងតំបន់។ យើងបានសាងសង់អគារការិយាល័យកណ្តាលថ្មី ដែលមានឈ្មោះថា អ៊ីសាន់ ថៅវើ (E.SUN TOWER) នៅលើ មហាវិថីព្រះមុន្នីវង្ស ដែលជាទីតាំងពាណិជ្ជកម្មសំខាន់នៅក្នុងរាជធានីភ្នំពេញ ហើយបានបើកសម្ពោធ នៅខែធ្នូ ឆ្នាំ ២០១៨ ។ អាគារនេះមានចំនួន ១៦ ជាន់ និងមានជាន់ក្រោមដីចំនួន ៤ ជាន់បន្ថែមទៀត ដែលបង្ហាញពីការតាំងចិត្តរបស់ធនាគារ សហាពាណិជ្ជ ក.អ ក្នុងការអភិវឌ្ឍន៍ដ៏ខ្លាំងក្លាក្នុងទីផ្សារហិរញ្ញវត្ថុកម្ពុជា។

ចំពោះការអភិវឌ្ឍន៍ផ្នែកអាជីវកម្មវិញ សាខាទាំង ១០ របស់ធនាគារ សហាពាណិជ្ជ ក.អ នៅក្នុងរាជធានីភ្នំពេញ បានបន្តបង្កើននូវចំនួនអតិថិជន ហើយយើងក៏បានបន្តពង្រឹងនូវសេវាប្រាក់បញ្ញើ ប្រាក់កម្ចីទិញផ្ទះ ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច ប័ណ្ណឥណទាន និងបង្កើនការបណ្តុះបណ្តាលសំរាប់បុគ្គលិក។ យើងនៅតែបន្តកែលម្អនូវគុណភាពសេវាកម្មឲ្យកាន់តែប្រសើ ដើម្បីថ្លែងអំណរគុណដល់ការគាំទ្ររបស់អតិថិជនចំពោះធនាគារ សហាពាណិជ្ជ ក.អ។ សេវាធនាគារឌីជីថល មានដូចជា សេវាធនាគារតាមអ៊ីនធឺណេត និងសេវាធនាគារតាមទូរស័ព្ទដៃ ត្រូវបានបង្កើតនិងបំពាក់នូវមុខងារថ្មី ដើម្បីផ្តល់ភាពងាយស្រួល និងបទពិសោធន៍សេវាកម្មហិរញ្ញវត្ថុល្អ ដល់អាជីវកម្មធុនតូច និងអតិថិជនទូទៅ។

ឆ្នាំ២០១៩ នៅតែជាឆ្នាំដែលមានភាពប្រែប្រួលបន្ថែមទៀតក្នុងស្ថានភាពសេដ្ឋកិច្ចអន្តរជាតិ។ កត្តាដូចជា ជំលោះពាណិជ្ជកម្មចិន និងអាមេរិក បញ្ហា Brexit និងការងើបឡើងយឺតនៃសេដ្ឋកិច្ចលោកខាងលិច

នៅតែបន្តប៉ះពាល់ដល់និន្នាការសេដ្ឋកិច្ចសកលលោក ដែលនៅតែជាបញ្ហាមិនអាចដោះស្រាយបាន។ ម៉្យាងវិញទៀត ការកើនឡើងនៃបណ្តាប្រទេសកំពុងរីកចម្រើន ការអនុវត្តន៍ការប្រើប្រាស់ថាមពលប្រកបដោយនិរន្តរភាព ការអភិវឌ្ឍន៍បច្ចេកវិទ្យានៃការធ្វើទំនាក់ទំនង កម្មវិធីដែលប្រើភាពវៃឆ្លាតសិប្បនិម្មិតជាដើម ធ្វើឱ្យការអភិវឌ្ឍរបស់ពិភពលោកពោរពេញទៅដោយការរំពឹងទុកមុន។ ដូច្នេះ ការបន្តកើនឡើងនៃវិនិយោគិនបរទេសមកវិនិយោគក្នុងប្រទេសកម្ពុជា គឺជាឱកាសយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍធនាគារ សហពាណិជ្ជ ក.អ ឲ្យកាន់តែរីកចំរើន ។

នាពេលអនាគត ឧស្សាហកម្មហិរញ្ញវត្ថុនឹងក្លាយជាកម្លាំងជំរុញដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍប្រទេស។ ធនាគារ សហពាណិជ្ជ ក.អ នឹងបន្តផ្តោតលើការបង្កើតតម្លៃអតិថិជន និងជួយដល់ការអភិវឌ្ឍន៍សហគ្រាស ស្របពេលជាមួយគ្នានេះដែរ បន្តរក្សាគុណភាពទ្រព្យសកម្ម និងស្ថេរភាពសន្ទនីយភាព បង្កើតនូវឥទ្ធិពលតាមរយៈការអនុវត្តន៍នូវទំនួលខុសត្រូវក្នុងសង្គម និងអភិវឌ្ឍន៍យុទ្ធសាស្ត្រផ្សេងៗ ដើម្បីបោះជំហានឲ្យទាន់និន្នាការថ្មីៗ និងសង្គមបច្ចុប្បន្ន។

# ២. ប្រវត្តិរបស់ធនាគារ សហពាណិជ្ជ ក.អ

## ធនាគារមេ៖ ធនាគារ E.SUN

ធនាគារ E.SUN ត្រូវបានបង្កើតឡើង នៅ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ១៩៩២ និង បើកដំណើរការអាជីវកម្ម នៅ ថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ១៩៩២។ ក្រោមការដឹកនាំរបស់លោក Huang Yung Jen ដែលជាស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន E.Sun Financial Holding រួមជាមួយនិងក្រុមឥស្សរជនផ្នែកហិរញ្ញវត្ថុមួយចំនួនទៀតដែលមានគំនិតដូចគ្នា។ E.SUN បានប្រកាន់ភ្ជាប់នូវទស្សនៈវិស័យនៃ "ជំនាញវិជ្ជាជីវៈ សេវាកម្ម និងពាណិជ្ជកម្ម" ក្នុងការគ្រប់គ្រង ហើយក៏ប្រកាន់ភ្ជាប់នូវគោលគំនិតដែលរួមមាន ការបណ្តុះបណ្តាលនូវអ្នកមានទេពកោសល្យ ការផ្តល់សេវាកម្មល្អបំផុតជូនអតិថិជន គឺជាការទំនួលខុសត្រូវរបស់ E.SUN។ នេះជាគោលគំនិតចំបងនៃសកម្មភាពក្នុងការគ្រប់គ្រង និងប្តេជ្ញាធ្វើជាគំរូក្នុងវិស័យហិរញ្ញវត្ថុ និងវិស័យសេវាកម្ម។

"ការបង្កើតស្តង់ដារ បណ្តុះបណ្តាលអ្នកមានទេពកោសល្យ អភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា"ជា គោលគំនិតធំៗទាំង៣របស់ ធនាគារ E.SUN។ គោលគំនិតស្នូលរបស់ E.SUN គឺ ត្រូវមានទឹកចិត្ត "ថ្លាដូចគុជ រឹងមាំដូចភ្នំ" រួមជាមួយការប្តេជ្ញាចិត្តផ្តល់នូវសេវាកម្មប្រកបទៅដោយជំនាញ និងភាពកក់ក្តៅជូនដល់អតិថិជន។ បន្ថែមពីលើនេះ បុគ្គលិករបស់ E.SUN ប្តេជ្ញាធ្វើជាប្រជាពលរដ្ឋដ៏ល្អ ហើយធនាគារ E.SUN ដែលពោលពេញទៅដោយក្តីស្រលាញ់ ក៏ប្តេជ្ញាធ្វើជាធនាគារលំដាប់ទី១ និងមានការយកចិត្តទុកដាក់លើការទំនួលខុសត្រូវក្នុងសង្គម។

ប្រឈមមុខជាមួយនឹងទីផ្សារដែលមិនអាចព្យាករបាន និងមានស្ថានភាពប្រកួតប្រជែងខ្ពស់ E.SUN នឹងនៅតែបន្តនាំយកនូវយុទ្ធសាស្រ្តដែលរឹងមាំ ប្រកបដោយគំនិតច្នៃប្រឌិត ព្រមទាំងសេវាកម្មដែលថ្មីនិងមានគុណភាពល្អដើម្បីជំនះនូវបញ្ហា និងបង្កើតនូវជម្រើសសេវាកម្មហិរញ្ញវត្ថុ យ៉ាងទូលំទូលាយជូនដល់អតិថិជន។ E.SUN បានពង្រីកសាខារបស់ខ្លួនរហូតដល់ ១៣៨ ហើយជឿជាក់ថាបណ្តាញទាំងនេះអាចបង្កើនប្រសិទ្ធភាព និងវិសាលភាពរបស់យើងកាន់តែខ្លាំងឡើង។ ចំណែកឯការវិវឌ្ឍន៍ផ្នែកបច្ចេកទេស យើងនឹងនាំយកនូវវិធីសាស្រ្តថ្មីៗដែលមានភាពបត់បែនខ្ពស់ និង ទំនើបក្នុងការដោះស្រាយបញ្ហាជាច្រើនប្រភេទ និងបំពេញតម្រូវការរបស់អតិថិជន រួមទាំងផ្តល់ជម្រើសនៃសេវាកម្មហិរញ្ញវត្ថុផ្សេងៗជាច្រើន ជូនដល់អតិថិជន។

ចំពោះវិសាលភាពក្រៅប្រទេសរបស់ខ្លួន ធនាគារ E.SUN មានធនាគារបុត្រសម្ព័ន្ធចំនួន២ ពោលគឺ ធនាគារ សហពាណិជ្ជ ក.អ នៅប្រទេសកម្ពុជា និង ធនាគារបុត្រសម្ព័ន្ធនៅប្រទេសចិន។ ក្រៅពីនេះ ធនាគារ E.SUN ទៀតដែលស្ថិតនៅ ទីក្រុងហុងកុង ទីក្រុង ក៏មានសាខាធនាគារចំនួន៧ Los Angeles ប្រទេសវៀតណាម សឹង្ហបុរី ភូមា ទីក្រុង Sydney ទីក្រុង Tokyo។ E.SUN ក៏កំពុងតែរៀបចំពង្រីកបណ្តាញរបស់ខ្លួនបន្ថែមទៀតក្នុងប្រទេស ចិន និង ទីតាំងដ៏ទៃទៀតនៃតំបន់អាស៊ីអាគ្នេយ៍។ E.SUN មានគោលដៅបង្កើត ឲ្យមាននូវបណ្តាញសេវាកម្មហិរញ្ញវត្ថុដែលប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងតំបន់អាស៊ី ព្រមទាំងអាចផ្តល់នូវសេវាកម្ម ដែលមានគុណភាពលំដាប់ខ្ពស់ជូនទៅដល់អតិថិជនក្នុងស្រុក ដែលមានតម្រូវការខាងសេវាកម្មហិរញ្ញវត្ថុក្រៅប្រទេស។

# ធនាគារ សហពាណិជ្ជ ក.អ

ធនាគារ សហពាណិជ្ជ ក.អ ត្រូវបានបង្កើតឡើង នៅ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ១៩៩៤ និង បច្ចុប្បន្នធនាគារ E.SUN បានកាន់កាប់ភាគហ៊ុន ១០០ក្នុងនាមជា ធនាគារបុត្រសម្ព័ន្ធរបស់ ។% ធនាគារE.SUN ធនាគារ សហពាណិជ្ជ ក.អ បានប្រកាន់ភ្ជាប់នូវ គុណតម្លៃ និង ទស្សនៈវិស័យ របស់ ធនាគារ E.SUN ដែលរួមមានការផ្តល់នូវសេវាកម្មយ៉ាងល្អបំផុត និង ការចូលរួមចំនែកក្នុងការអភិវឌ្ឍន៍សង្គម ។ នាពេលអនាគត ធនាគារ សហពាណិជ្ជ ក.អ នឹងបន្តពង្រឹងទៅលើផលិតផល សេវាកម្ម និងគំនិតច្នៃប្រឌិត ខាងផ្នែកហិរញ្ញវត្ថុ ជាមួយគ្នានោះដែរ នឹងបន្តផ្តោតសំខាន់ទៅលើការបណ្តុះបណ្តាលទៅលើធនធានមនុស្សក្នុងស្រុកដែលមានទេពកោសល្យ និង ជំរុញឲ្យមានការសហការ ព្រមទាំង ការដោះដូរបទពិសោធន៍រវាងអ្នកជំនាញមកពីប្រទេសផ្សេងៗគ្នា ជំរុញឲ្យមានការច្នៃប្រឌិតផ្សេងៗកើតឡើង ដើម្បីកសាងធនាគារ សហពាណិជ្ជ ក.អ ឲ្យក្លាយជាធនាគារ ក្រៅស្រុកមួយ ដែលមានភាពពិសេសជាងគេ ក្នុងប្រទេសកម្ពុជា។

# ៣. ទិដ្ឋភាពទូទៅនៃអាជីវកម្ម

## 1. ចំនុចសំខាន់ខ្លះៗនៃរបាយការណ៍ហិរញ្ញវត្ថុ

| | ២០១៧ | ២០១៦ | ២០១៥ |
|---|---|---|---|
| **លទ្ធផលនៃចំណូលប្រតិបត្តិការ (ដុល្លារ)** | | | |
| ចំណូលប្រតិបត្តិការ | ៣២.២៦៥.៤៦៨ | ២៣.១៥៥.២៤៥ | ២០.៩០៣.៣១៦ |
| ប្រាក់ចំណេញមុនចំណាយលពន្ធ | ៥.៦៨៧.១២១ | (២៥.៦២១.៥៣៦) | (២២.២៨៧.៥៨១) |
| ប្រាក់ចំណេញសុទ្ធ | ៤.៣៧១.១១៧ | (២០.៣៤១.២៦៥) | (១៨.៥០៦.៤២៨) |
| **ទិន្នន័យសំខាន់ៗរបស់តារាងតុល្យការ (ដុល្លារ)** | | | |
| ទ្រព្យសកម្មសរុប | ៥១៧.៧២៣.៥៨១ | ៥៥៣.២៥៨.០០២ | ៦០២.៩៦១.៦៧៦ |
| ឥណទានសំរាប់អតិថិជន (សុទ្ធ) | ៣១៥.៤២៤.១៩៨ | ៣១៦.៤០៨.៦៣៧ | ៣៩៤.០៥៤.៤៩៧ |
| ប្រាក់បញ្ញើររបស់អតិថិជន | ៣៣១.០២៥.៦៤១ | ២៧៩.៥១២.៥៨០ | ៣៨៣.៦៧១.៦៧៧ |
| បំណុលសរុប | ៩៤១.៤៤៨.៦២៣ | ៤៦១.០៤៧.៣៣៨ | ៥៥៣.០១៦.៥០២ |
| ដើមទុនបានបង់ | ៨០.០០០.០០០ | ៨០.០០០.០០០ | ៣៧.៥០០.០០០ |
| មូលនិធិភាគទុនិក | ៧៦.២៧៤.៩៥៨ | ៧២.២១០.៦៦៤ | ៤៩.៩៤៥.១៧៤ |
| ផលរបរលើទ្រព្យសកម្ម | ០.៨៤% | (៣.៨១%) | (៣.០៧%) |
| ផលរបរលើដើមទុន | ៥.៧៣% | (២៨.១៧%) | (៣៧.០៥%) |
| បំណុលមិនដំណើរការ % | ៣.៤៤% | ៧.៣៤% | ១៤.៧៧% |
| **អនុបាតមូលដ្ឋាន** | | | |
| អនុបាតសោធនភាព | ៣០.៧៩% | ៣១.៤៤% | ១៦.៦៧% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ១១០% | ១៤៧% | ១២៨% |
| អនុបាតសន្ទនីយភាព | - | - | - |

## 2. ព្រឹត្តិការណ៍សំខាន់នៃអាជីវកម្ម

- **ការវិវត្តន៍នៃគំរោង និង ការអភិវឌ្ឍន៍នៃហេដ្ឋារចនាសម្ព័ន្ធ**

❖ **អាគារទីស្នាក់ការកណ្តាលថ្មី**

អាគារស្នាក់ទីការកណ្តាលថ្មីរបស់យើង E.SUN Tower ត្រូវបានសាង់សង់រួចរាល់ជាស្ថាពរ និងបានបើកសម្ពោធនៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៨។ អាគារនេះ ស្ថិតនៅតាមមហាវិថីព្រះមុនីវង្ស និង នៅចំកណ្តាលនៃទីក្រុងភ្នំពេញ។ អាគារនេះ ត្រូវបានសាងសង់ឡើងដោយក្រុមហ៊ុនសំណង់ដ៏ល្បី ឈ្មោះថា LBL INTERNATIONAL ហើយអាគារនេះនឹងជាទីស្នាក់ការចំបងសំរាប់ការធ្វើប្រតិបត្តិការរបស់ធនាគារ សហពាណិជ្ជ ក.អ ក្នុងការផ្តល់ នូវសេវាកម្ម លំដាប់ខ្ពស់ជូនដល់អតិថិជនដ៏មានតម្លៃរបស់យើង។

❖ **ប្រព័ន្ធបច្ចេកវិទ្យាពត៌មាន**

ចាប់តាំងពីបង្កើតឡើង ក្រុមហ៊ុនមេរបស់យើងគឺ ធនាគារ E.SUN បានចាត់ទុកថា "ការបង្កើតប្រព័ន្ធបច្ចេកវិទ្យា" "ការបណ្តុះបណ្តាលធនធានមនុស្ស" និង "ការអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មានវិទ្យា" ជាសរសស្តម្ភទាំងបីនៃដំណើរស្វែងរកនិរន្តរភាពយូរអង្វែងរបស់ខ្លួន។ ក្នុងចំណោម សរសស្តម្ភទាំងនេះ ប្រព័ន្ធព័ត៌មានវិទ្យាដើរតួសំខាន់បំផុតសម្រាប់រក្សា ដំណើរការអាជីវកម្មប្រចាំថ្ងៃ និងប្រសិទ្ធភាពនៃការធ្វើប្រតិបត្តិការរបស់ធនាគារ។ ក្នុងឆ្នាំ ២០១៧ ធនាគារសហពាណិជ្ជ ក.អ បានធ្វើការកែលម្អប្រព័ន្ធស្នូលរបស់ធនាគារក្នុង ការបង្កើនប្រសិទ្ធភាព នៃការធ្វើប្រតិបត្តិការ និងការគ្រប់គ្រងអាជីវកម្ម។ ការបើកដំណើរការនៃប្រព័ន្ធ GAML System ក្នុងការជួយការងាររបស់ AML/CFT និងកាត់បន្ថយហានិភ័យដែលពាក់ព័ន្ធ។ បន្ថែមពីលើនេះ ធនាគារក៏បានភ្ជាប់នូវប្រព័ន្ធ Fast Payment ដែលជួយបង្កើនប្រសិទ្ធភាពនៃការផ្ទេរប្រាក់រវាងធនាគារនិងធនាគារ ព្រមទាំង ការធ្វើប្រតិបត្តិការជាប្រាក់រៀលសំរាប់អតិថិជនយើង។ ជាងនេះទៅទៀត ធនាគារសហពាណិជ្ជ ក.អ នឹងដាក់ដំណើរការសេវាកម្មហិរញ្ញវត្ថុលើទូរស័ព្ទ នៅដើមឆ្នាំ ២០១៩ នេះ ហើយយើងជឿជាក់ថា

តាមរយៈការផ្តល់សេវាកម្មហិរញ្ញវត្ថុលើទូរស័ព្ទ ធនាគារសហពាណិជ្ជ ក.អ និងការផ្តល់សេវាកាន់តែផ្តល់ភាពងាយស្រួល ជូនដល់អតិថិជនរបស់យើង។

- **ក្រុមការងារជំនាញពហុសាសន៍**

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ធនាគារ សហពាណិជ្ជ ក.អ. បន្តយ៉ាងសកម្មក្នុងការជ្រើសរើសអ្នកមានទេព្យកោលស្យ និងអ្នកជំនាញក្នុងស្រុកឲ្យចូលបម្រើការងារ។ ដោយមានការរួមគ្នារវាងអ្នកជំនាញមកពីតៃវ៉ាន់ និងអ្នកជំនាញក្នុងស្រុកដែលសុទ្ធតែពោរពេញដោយបទពិសោធន៍ ធនាគារ សហពាណិជ្ជ ក.អ. បានបង្កើតនូវក្រុមការងារជំនាញពហុសាសន៍ក្នុងគោលបំណងធ្វើឲ្យធនាគារ សហពាណិជ្ជ ក.អ. ក្លាយជាធនាគារបរទេសពិសេសមួយក្នុងប្រទេសកម្ពុជា។ ទោះបីជាដូច្នេះក៏ដោយ ក៏ធនាគារ សហពាណិជ្ជ ក.អ. នៅតែបន្តពង្រឹងការបណ្តុះបណ្តាលចំណេះដឹងដល់បុគ្គលិករបស់ខ្លួន តាំងពីអាកប្បកិរិយាក្នុងការផ្តល់សេវាកម្ម រហូតដល់ចំណេះដឹងខាងផ្នែកជំនាញវិជ្ជាជីវៈ ដើម្បីធានាថាអតិថិជនដ៏មានតម្លៃរបស់យើង ទទួលបាននូវការបម្រើសេវាកម្មប្រកបដោយគុណភាព និងបទពិសោធន៍ល្អជាមួយធនាគារ។

- **សេវាកម្មឈានមុខ**

ធនាគារ សហពាណិជ្ជ ក.អ. បន្តផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដែលមានគុណភាពខ្ពស់ និងឈានមុខគេ ដល់អតិថិជនដ៏មានតម្លៃរបស់យើង និងកសាងកេរ្តិ៍ឈ្មោះរបស់ខ្លួនលើទីផ្សារ។ ចំពោះសេវាកម្មប័ណ្ណឥណទាន បច្ចុប្បន្ននេះ ធនាគារ សហពាណិជ្ជ ក.អ. ស្ថិតក្នុងចំណាត់ថ្នាក់លេខ ២ ក្នុងការចែកចាយប័ណ្ណឥណទានលើទីផ្សារប្រទេសកម្ពុជា និងទទួលបានពានរង្វាន់អន្តរជាតិជាច្រើនពីប័ណ្ណឥណទាន និងឥណទានវីសា។ ធនាគារ សហពាណិជ្ជ ក.អ. នឹងបន្តអភិវឌ្ឍន៍ប័ណ្ណឥណទានឲ្យក្លាយជាពាណិជ្ជសញ្ញាមួយដែលទទួលបានការពេញនិយមបំផុតពីសំណាក់ប្រជាជនកម្ពុជា។ ធនាគារសហពាណិជ្ជ ក.អ. នឹងផ្តោតការយកចិត្តទុកដាក់ផងដែរ លើសេវាកម្មកម្ចីសម្រាប់អាជីវកម្ម និងកម្ចីទិញផ្ទះ ដែលជាកត្តាជម្រុញឲ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

- **ការគ្រប់គ្រងហានិភ័យ**

ក្នុងឆ្នាំ ២០១៧ ធនាគារសហពាណិជ្ជ ក.អ បានបង្កើតនាយកដ្ឋានគ្រប់គ្រងហានិភ័យឯករាជ្យមួយដែលមានមុខងារពិនិត្យលើសកម្មភាពគ្រប់គ្រងហានិភ័យរបស់ធនាគារ ត្រួតពិនិត្យទៅលើហានិភ័យផ្សេងៗដែលពាក់ព័ន្ធនិងធនាគារដូចជា ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យបំលែងសាច់ប្រាក់ ហានិភ័យទីផ្សារ និងហានិភ័យសុវត្ថិភាពព័ត៌មាន ហើយត្រូវរាយការណ៍ដោយផ្ទាល់ទៅគណកម្មាការគ្រប់គ្រងហានិភ័យ ឬ ក្រុមប្រឹក្សាភិបាលរបស់ធនាគារ។

- **ការចូលរួមចំណែកក្នុងសង្គម**

ធនាគារ សហពាណិជ្ជ ក.អ. ប្រកាន់ខ្ជាប់នូវគោលគំនិតអភិវឌ្ឍន៍ ប្រកបដោយនិរន្តរភាពរបស់ក្រុមហ៊ុនមេរបស់យើងពោលគឺ ធនាគារ E.SUN ហើយក៏ផ្តោតការយកចិត្តទុកដាក់លើការងារពាក់ព័ន្ធនឹងអត្ថប្រយោជន៍របស់ម្ចាស់ភាគហ៊ុន ។ យើងខិតខំព្យាយាមអស់ពីលទ្ធភាពក្នុងការធ្វើឲ្យសង្គមមានភាពល្អប្រសើរ ហើយបង្ហាញពីក្តីស្រលាញ់របស់យើងចំពោះសង្គម តាមរយៈសកម្មភាពសប្បុរសធម៌នានា។ ជាក់ស្តែងក្នុងឆ្នាំ២០១៨ យើងបានសហការជាមួយធនាគារ E.SUN បង្កើតឲ្យមានក្រុមការងារស្ម័គ្រចិត្ត ដើម្បីចុះទៅជួយសាងសង់ផ្ទះជូនប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ដាច់ស្រយាលក្នុងខេត្តសៀមរាប និងបានសហការជាមួយមន្ទីរពេទ្យ Mackay Memorial Hospital របស់តៃវ៉ាន់ ក្នុងការបង្កើតក្រុមការងារស្ម័គ្រចិត្តផ្នែកសុខភាព ដើម្បីជួយផ្តល់សេវាសុខភាពសប្បុរសធម៌ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដាច់ស្រយាលក្នុងរាជធានីភ្នំពេញ។

## 3. គោលនយោបាយឆ្នាំ ២០១៩

ទីផ្សារធនាគារកម្ពុជាត្រូវបានគ្របដណ្តប់ដោយក្រុមធំៗចំនួនពីរ គឺធនាគារដែលគ្រប់គ្រងដោយក្រុមហ៊ុនបរទេស និងធនាគារធំៗក្នុងស្រុក។ នៅចុងឆ្នាំ ២០១៨ មានធនាគារពាណិជ្ជចំនួន ៤៣ ធនាគារឯកទេសចំនួន ១៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៨០ (MFIs និង MDIs) ។ ធនាគារសហពាណិជ្ជ ក.អ. មានសំណាងណាស់ ដែលបានបង្កើតទំនាក់ទំនងយ៉ាងមានផ្លែផ្កាជាមួយសហគមន៍ក្នុងស្រុក និងអ្នកវិនិយោគមកពីតៃវ៉ាន់ ដែលធ្វើឲ្យមានអតិថិជនស្មោះត្រង់ និង គាំទ្រជាច្រើន។

វិស័យសេវាកម្មហិរញ្ញវត្ថុដើរតួយ៉ាងសំខាន់ នៅក្នុងវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកលើមូលដ្ឋានប្រាក់ដុល្លា ហើយធនាគារពាណិជ្ជភាគច្រើនផ្តល់ប្រាក់កម្ចីជាប្រាក់ដុល្លារ ដើម្បីផ្តល់ហិរញ្ញប្បទានដល់ពាណិជ្ជកម្ម ផលិតកម្ម និងសេវាកម្ម។ ទោះបីជាប្រាក់រៀលជារូបិយវត្ថុជាតិក៏ដោយ ប្រាក់កម្ចីភាគច្រើនផ្តល់ជាប្រាក់ដុល្លារជាជាងរូបិយវត្ថុជាតិ។ ចំពោះបញ្ហានេះ នៅក្នុងក្របខ័ណ្ឌនៃគោលនយោបាយផ្លាស់ប្តូរប្រាក់ដុល្លារ ធនាគារជាតិនៃកម្ពុជាបានចេញបទបញ្ញាថ្មីនៅក្នុងខែធ្នូ ឆ្នាំ ២០១៦ ដែលតម្រូវឱ្យធនាគារមានប្រាក់កម្ចីជាប្រាក់រៀលយ៉ាងហោចណាស់ ១០% នៃផលប័ត្រកម្ចីសរុបរបស់ខ្លួននៅចុងឆ្នាំ ២០១៩ ។

- **សេវាកម្មសន្សំ និងសាខា**
  - ក្នុងរយៈពេលបីឆ្នាំខាងមុខ ធនាគារនឹងបន្តស្រូបយកប្រាក់បញ្ញើសន្សំ/បញ្ញើតាមតម្រូវការ ជាពិសេសពីអតិថិជនក្រុមហ៊ុន ។ ទន្ទឹមនឹងនេះដែរ ធនាគារនឹងបន្តពង្រឹងគុណភាពសេវាកម្ម និងផ្តល់សេវាកម្មឲ្យកាន់តែប្រសើរ ដល់អតិថិជនដ៏មានតម្លៃទាំងក្នុង និងក្រៅប្រទេសរបស់ធនាគារ។ ដើម្បីឲ្យសម្រេចបាន ធនាគារនឹងពង្រឹងសេវាគ្រប់គ្រងសាច់ប្រាក់របស់ខ្លួន ដូចជាសេវាធនាគារតាមអ៊ីនធឺណិត និងសេវាធនាគារតាមទូរសព្ទ ហើយចាប់ផ្តើមផ្តល់សេវាជាភាសាចិន ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃការវិនិយោគផ្ទាល់ពីប្រទេសចិន។ ជាងនេះទៅទៀត ជាមួយនឹងក្រុមការងារគ្រប់គ្រងអតិថិជន VIP របស់ធនាគារ អតិថិជន VIP នឹងទទួលបានសេវាកម្មដែលមានភាពបត់បែន។

- **សេវាកម្មឥណទាន**
  - សម្រាប់ការកើនឡើងនៃប្រជាជនដែលមានកម្រិតជីវភាពមធ្យម និងចំនួនប្រជាជនសរុបនៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ធនាគារនឹងផ្តោតលើសេវាកម្មឥណទានគេហដ្ឋានសម្រាប់បំពេញតម្រូវការរបស់គ្រួសារនីមួយៗនៅក្នុងប្រទេសកម្ពុជា និងមានបំណងក្លាយជាអ្នកផ្តល់ប្រាក់កម្ចីទិញផ្ទះចំបង នៅក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា។ ចំពោះឥណទានសំរាប់អាជីវកម្ម ធនាគារនឹងផ្តោតលើអតិថិជនដែលមានសក្តានុពល ក្នុងវិស័យលក់រាយ វិស័យផលិតកម្ម និងក្រុមហ៊ុនពហុជាតិនានា។ ប៉ុន្តែ

យើងនឹងបញ្ចៀសការផ្តល់ឥណទានដែលមានទំហំធំ និងប្រភេទអតិថិជនក្នុងវិស័យដែលមានហានិភ័យខ្ពស់។

- ❖ នៅក្នុងការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិការផ្ទៃក្នុង ធនាគារប្រមូលផ្តុំប្រតិបត្តិការឥណទាន ដូចជាការវាយតម្លៃលើវត្ថុបញ្ចាំ ការវិភាគ និងការវាយតម្លៃឥណទាន ការផ្តល់ប្រាក់កម្ចី និងការគ្រប់គ្រងឯកសារ ទៅទីស្នាក់ការកណ្តាល។ ការធ្វើបែបនេះនឹងបង្កើនប្រសិទ្ធភាពនៃប្រតិបត្តិការ និងកាត់បន្ថយហានិភ័យប្រតិបត្តិការ ក៏ដូចជាការក្លែងបន្លំផ្សេងៗ។ម្យ៉ាងវិញទៀត ធនាគារនឹងពង្រឹងសមត្ថភាពនៃការទារបំណុលអាក្រក់ ជាពិសេសការអនុវត្តតាមផ្លូវច្បាប់ យន្តការផ្តល់ដំណឹងអំពីប្រាក់កម្ចីមានបញ្ហា និងការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ។

## ○ សេវាកម្មប័ណ្ណឥណទាន

- ❖ អាជីវកម្មប័ណ្ណឥណទាន នឹងផ្តោតយុទ្ធសាស្ត្ររបស់ខ្លួនទៅលើអតិថិជន VIP ហើយនិងផ្សព្វផ្សាយនូវកេរ្តិ៍ឈ្មោះយីហោរបស់ខ្លួន។ ធនាគារបានចាប់ផ្តើមផលិតប័ណ្ណឥណពន្ធរបស់ខ្លួននៅក្នុងឆមាសទី ២ ឆ្នាំ ២០១៩ ដើម្បីពង្រឹងវិសាលភាពនៃសេវាកម្ម។ ប័ណ្ណឥណពន្ធដែលបញ្ចូលមុខងាររបស់កាតអេធីអឹម នឹងបម្រើសេវាកម្មដល់អតិថិជនទូទៅ និងអតិថិជនដែលធ្វើការចាយវាយនៅក្រៅប្រទេស ហើយនេះកាន់តែផ្តល់ភាពងាយស្រួលដល់អតិថិជនរបស់ធនាគារ។

- ❖ ចំពោះការគ្រប់គ្រងផ្ទៃក្នុង អាជីវកម្មប័ណ្ណឥណទាននឹងពង្រឹងប្រសិទ្ធភាព និងសមត្ថភាពគ្រប់គ្រងហានិភ័យរបស់ខ្លួនដោយការអភិវឌ្ឍន៍ប្រព័ន្ធ IT និងដំណើរការអាជីវកម្មឡើងវិញ។ ជាក់ស្តែង ធនាគារនឹងប្រើប្រាស់កម្មវិធីបច្ចេកវិទ្យាបន្ថែម ដើម្បីអនុវត្តការវិភាគទិន្នន័យ ការគ្រប់គ្រងលើការទទួល ប្រព័ន្ធសារអក្សរ និងជួយបង្កើនសុវត្ថិភាពប្រតិបត្តិការ និង កិច្ចការគ្រប់គ្រងទំនាក់ទំនងអតិថិជនក្នុងអាជីវកម្មនេះប័ណ្ណឥណទាន។

# ៨. សកម្មភាព និង ការខួបគួម្ព




*ការិយាល័យកណ្តាលថ្មីរបស់ធនាគារ UCB អគារអ៊ីសាន់ ថៅវើ*
*ពិធីបើកសម្ពោធនៅសណ្ឋាគារសូហ្វីតែលរាជធានីភ្នំពេញ*

## នេះជាការចាប់ផ្តើមនៃយុគសម័យថ្មីរបស់ UCB



*ស្ថាបនិកនៃ E.SUN FHC*
*ជាមួយគណៈគ្រប់គ្រងប្រារព្ធពិធីសម្ពោធទីស្នាក់ការកណ្តាលថ្មីរបស់ធនាគារ UCB*

# ការប្តេជ្ញាចិត្តដើម្បី និរន្តរភាពនៃ អាជីវកម្ម




នាយកប្រតិបត្តិដឹកនាំក្រុម UCBers ដើម្បីសំអាតបរិស្ថាននៅតាមខេត្តដាច់ស្រយាល




ព្រឹត្តិការណ៍អ្នកស្ម័គ្រចិត្តឆ្នាំ 2018 ជាមួយធនាគារអ៊ីសាន់
នៅក្នុងខេត្តសៀមរាប



# ៨. អភិបាលកិច្ចសាជីវកម្ម

## អង្គការលេខរបស់ធនាគារ UCB

គំនូសតាងព័ត៌មានលំអិតស្តីពីអង្គការលេខរបស់ធនាគារ UCB.




កាលបរិច្ឆេទរបស់ទិន្នន័យ: **2018/12/31**

កាលបរិច្ឆេទរបស់ទិន្នន័យ: 2018/12/31

## ក្រុមប្រឹក្សាភិបាលរបស់ធនាគារ UCB

តារាងព័ត៌មានលំអិតស្ដីពីសមាសភាពក្រុមប្រឹក្សាភិបាលរបស់ធនាគារ UCB

| № | ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទ ជ្រើសតាំង | បច្ចុប្បន្នចំនួនហ៊ុនកាន់កាប់ | | កំរិតសិក្សា |
|---|---|---|---|---|---|---|
| | | | | ចំនួនប័ណ្ណភាគហ៊ុន | អនុបាត | |
| ១ | តំណាងពីធនាគារ E.SUN Bank Mr. Mao-Chin Chen | ប្រធានក្រុមប្រឹក្សាភិបាល | ២២ ឧសភា ២០១៧ | | | Master of Economics National Taiwan University |
| ២ | តំណាងពីធនាគារ E.SUN Bank Ms. I Yen-Kuo | អភិបាល | ៣០ មិនា ២០១៧ | | | Master of Economics National Taiwan University |
| ៣ | តំណាងពីធនាគារ E.SUN Bank Mr. Chi Kan-Chung | អភិបាលនិងអគ្គនាយក | ៣០ មិនា ២០១៧ | ៨.000 | ១០០% | Bachelor of Economic Fu Ren University |
| ៤ | តំណាងពីធនាគារ E.SUN Bank Mr. Chieh Hung-Chen | អភិបាល | ២២ ឧសភា ២០១៧ | | | Master of Business Administration Drexel University |
| ៥ | Ms. Hun Phalin | អភិបាល | ៣០ មិនា ២០១៧ | | | Bachelor of Art Option Chinese Language Beijing Language and Culture University |
| ៦ | Mr. Tung-Lung Kuo | អភិបាលឯករាជ្យ | ២២ ឧសភា ២០១៧ | | | Bachelor of Law in Public Administration National Taipei University |
| ៧ | Mr. Chuan-Hsing Huang | អភិបាលឯករាជ្យ | ៣០ មិនា ២០១៧ | | | Doctor Degree of Philosophy Tamkang University |

ប្រធានក្រុមប្រឹក្សាភិបាល អគ្គនាយកប្រតិបត្តិ គណៈគ្រប់គ្រងឬបុគ្គលពាក់ព័ន្ធ ត្រូវទទួលខុសត្រូវពីបញ្ហាហិរញ្ញវត្ថុ និងគណនេយ្យនាកាលបរិច្ឆេទគ្រាមុនដែលបានធ្វើការជាមួយក្រុមហ៊ុន CPA ឬសាខារបស់ខ្លួន។

ទេ

ចាប់តាំងពីសារពើពន្ធមុនមកដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ គណៈនាយកមានគំនិតផ្សេងគ្នា និងបានសរសេររបាយការណ៍ដំណោះស្រាយជាលាយលក្ខ័អក្សរដាក់ជូនក្រុមប្រឹក្សាភិបាល។

ដំណោះស្រាយទាំងអស់ត្រូវបានដាក់ជូន និងអនុម័តដោយក្រុមប្រឹក្សាភិបាលទាំងអស់ ដោយគ្មានការខ្វែងគំនិតគ្នា។

## គណៈកម្មការសវនកម្មរបស់ធនាគារ UCB

តារាងព័ត៌មានលំអិតស្តីពីសមាសភាពគណៈកម្មការសវនកម្មរបស់ធនាគារ UCB:

| Nº | មុខតំណែង | គោត្តនាមនិងនាម | មុខតំណែង | គោត្តនាមនិងនាម |
|---|---|---|---|---|
| ១ | ប្រធានគណៈកម្មការ | **Mr. Tung-Lung Kuo** | ២២ ឧសភា ២០១៧ | Bachelor of Law in Public Administration<br>National Taipei University |
| ២ | សមាជិក | **Mr. Mao-Chin Chen** | ២២ ឧសភា ២០១៧ | Master of Economics<br>National Taiwan University |
| ៣ | សមាជិក | **Mr. Chuan-Hsing Huang** | ៣០ មិនា ២០១៧ | Doctor Degree of Philosophy<br>Tamkang University |
| ៤ | សមាជិក | **Ms. I-Yen Kuo** | ៣០ មិនា ២០១៧ | Master of Economics<br>National Taiwan University |

## គណៈកម្មការគ្រប់គ្រងហានិភ័យរបស់ធនាគារ UCB

តារាងព័ត៌មានលំអិតស្តីពីសមាសភាពគណៈកម្មាការគ្រប់គ្រងហានិភ័យរបស់ធនាគារ UCB:

| Nº | មុខតំណែង | គោត្តនាមនិងនាម | មុខតំណែង | គោត្តនាមនិងនាម |
|---|---|---|---|---|
| ១ | ប្រធានគណៈកម្មការ | **Mr. Chuan-Hsing Huang** | ៣០ មិនា ២០១៧ | Doctor Degree of Philosophy<br>Tamkang University |
| ២ | សមាជិក | **Mr. Mao Chin-Chen** | ២២ ឧសភា ២០១៧ | Master of Economics<br>National Taiwan University |
| ៣ | សមាជិក | **Mr. Chi-Kan Chung** | ៣០ មិនា ២០១៧ | Bachelor of Economic<br>Fu Ren University |
| ៤ | សមាជិក | **Mr. Chieh-Hung Chen** | ២២ ឧសភា ២០១៧ | Master of Business Administration<br>Drexel University |

# ៦. របាយការណ៍ក្រុមប្រឹក្សាភិបាល

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីរីករាយសូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ធនាគារ សហពាណិជ្ជ ក.អ. (ហៅកាត់ថា "ធនាគារ") និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ ដែលតទៅនេះទាំងធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវហៅកាត់ថា ("សម្ព័ន្ធធនាគារ") និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ធនាគារសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ។

### សកម្មភាពចម្បង

ធនាគារ គឺជាធនាគារពាណិជ្ជ ដែលកំពុងធ្វើប្រតិបត្តិការ ក្រោមបទប្បញ្ញត្តិនៃធនាគារជាតិនៃកម្ពុជា និងអនុលោមទៅតាមអាជ្ញាប័ណ្ណរបស់ធនាគារលេខ ០៨ ចេញដោយធនាគារជាតិនៃកម្ពុជា ។ អនុលោមតាមប្រកាសលេខ ធ៧-០៦-២០៧ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៦ អាជ្ញាប័ណ្ណរបស់ធនាគារ ត្រូវបានបន្តជាថ្មី ជាអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៦ ។

សកម្មភាពចម្បងរបស់ធនាគារដែលធ្វើប្រតិបត្តិការតាមរយៈស្នាក់ការកណ្តាលរបស់ធនាគារ និងបណ្តាសាខានានាក្នុងព្រះរាជាណាចក្រកម្ពុជាមានដូចជា៖ ទទួលប្រាក់បញ្ញើរយៈពេលខ្លី មធ្យម និងវែងពីស្ថាប័នផ្សេងៗ និង ឯកត្តជន និងធ្វើការផ្តល់ឥណទាន និងបុរេប្រទានរយៈពេលខ្លី មធ្យម និងវែងជូនស្ថាប័នផ្សេងៗ និងអតិថិជន ផ្តល់សេវាកម្មប្តូររូបិយវត្ថុបរទេស សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មអន្តរជាតិ អប្បហារកម្មមូលបត្រ ពាណិជ្ជកម្ម សេវាកម្មប្រតិបត្តិការរវាងអតិថិជន និងធនាគារផ្សេងៗទៀត ដែលបានអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា ។

### អំពីក្រុមហ៊ុនបុត្រសម្ព័ន្ធ

ក្រុមហ៊ុន យូអអុី លែន ហូលឌីង ខូ អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុនបុត្រសម្ព័ន្ធ") ត្រូវបានចុះបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣ ។ សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺកាន់កាប់ដីសម្រាប់ធនាគារប្រើប្រាស់ ។

### លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ មានដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| **សម្ព័ន្ធធនាគារ** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធលើប្រាក់ចំណេញ | ៥.៦៨៧.១២១ | ២២.៨៥០.៨៥២ | (២៥.៦២១.៥៣៦) | (១០៣.៨៣៨.១៩១) |
| (ចំណាយ)/ឥណទានពន្ធលើប្រាក់ចំណេញ | (១.៣១៦.០០៥) | (៥.២៨៧.៧០៥) | ៥.២៨០.២៧១ | ២១.៣១៦.៨៥៥ |

| | | | | |
|---|---|---|---|---|
| ប្រាក់ចំណេញ/(ខាត)សុទ្ធ សម្រាប់ការិយបរិច្ឆេទ | ៤.៣៧១.១១៧ | ១៧.៥៦៣.១៤៨ | (២០.៣៤១.២៦៥) | (៨២.១១៧.៦៨៧) |

# ធនាគារ សហពាណិជ្ជ ក.អ. និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

## លទ្ធផលហិរញ្ញវត្ថុ (ត)

| ធនាគារ | ២០១៨ ដុល្លារអាមេរិក | ២០១៨ ពាន់រៀល (កំណត់សំគាល់ ៤) | ២០១៧ ដុល្លារអាមេរិក | ២០១៧ ពាន់រៀល (កំណត់សំគាល់ ៤) |
|---|---|---|---|---|
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធលើប្រាក់ចំណេញ | ៤.៨១៩.៨៤១ | ១៩.៣៦៤.៥១៣ | (២៥.៥៩៤.៥៨៩) | (១០៣.៣២៥.៣៥៦) |
| (ចំណាយ)/ឥណទានពន្ធលើប្រាក់ចំណេញ | (១.១១៦.៣៧៣) | (៤.៤៨៥.៥៨៧) | ៥.៣១៥.៥១៧ | ២១.៤៥៨.៧៤២ |
| ប្រាក់ចំណេញ/(ខាត)សុទ្ធសម្រាប់ការិយបរិច្ឆេទ | ៣.៧០៣.០៦៨ | ១៤.៨៧៨.៩២៦ | (២០.២៧៩.០៧២) | (៨១.៨៦៦.៦១៤) |

### ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមានអនុសាសន៍ឲ្យមានការបែងចែកភាគលាភ សម្រាប់ការិយបរិច្ឆេទ នេះទេ ។

### ដើមទុន

នាថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៧ និង ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ធនាគារបានទទួលសាច់ប្រាក់បន្ថែមក្នុងការបង្កើនដើមទុនពីភាគទុនិកចំនួន ៤២.៥០០.០០០ ដុល្លារអាមេរិក។ ការបង្កើនដើមទុនត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧ និងអនុម័តដោយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៩ ។

### ឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទាន និងបុរេប្រទាន អាក្រក់ និងការធ្វើសំវិធានធនលើឥណទាន និងបុរេប្រទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលមានការជឿជាក់ថារាល់ឥណទាន និងបុរេប្រទាន ដែលបានដឹងថាមិនអាចទារបានត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងសម្រាប់ឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីស្ថានភាពណាមួយដែលនឹងបណ្តាលឲ្យចំនួននៃការលុបបំបាត់ចោលឥណទាន និងបុរេប្រទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទាន និងបុរេប្រទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនខ្វះខាត ជាសារវន្តនោះឡើយ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល បានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្តទាំងអស់ លើកលែងតែ បំណុលដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ហើយសន្និដ្ឋានថា មានតម្លៃមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃ ដែលគិតថានឹងអាចប្រមូលបាន ជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការ កំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ថាមានភាពមិនត្រឹមត្រូវនោះទេ ។

## វិធីសាស្រ្តវាយតម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ដែលធ្វើ ឲ្យប៉ះពាល់ដល់ការអនុវត្ត វិធីសាស្រ្តដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុង របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះពុំមានៈ

(ក) ការដាក់បញ្ចាំនូវទ្រព្យសកម្មណាមួយរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានធ្វើឡើងចាប់តាំងពីថ្ងៃ ចុងការិយបរិច្ឆេទ ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះសម្ព័ន្ធធនាគារ ឬធនាគារ ចាប់តាំងពីថ្ងៃចុង ការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារឡើយ ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់សម្ព័ន្ធធនាគារ និង ធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែបន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទដែល នឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការ បំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់នោះទេ ។

## ការប្រែប្រួលសភាពការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញសភាពការណ៍ណាមួយដែលមិនបានវែកញែក នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលនឹងបណ្តាលឲ្យមាន តួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេល ចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

នាថ្ងៃចេញរបាយការណ៍នេះ លើកលែងតែព្រឹត្តិការណ៍ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ពុំមានព្រឹត្តិការណ៍ណាមួយដែលកើតឡើងជាសារវន្ត បន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទ ដែលធ្វើឲ្យមានការធ្វើនិយ័តភាព និងធ្វើការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបានបម្រើការក្នុងឆ្នាំ និងនាថ្ងៃដែលចេញរបាយការណ៍នេះរួមមាន៖

| | |
|---|---|
| លោក Mao-Chin Chen | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Chi-Kan Chung | អភិបាល |
| លោកស្រី I-Yen Kuo | អភិបាល |
| លោកស្រី Hun Phaliin | អភិបាល |
| លោក Chien-Hung Chen | អភិបាល |
| លោក Tung-Lung Kuo | អភិបាលឯករាជ្យ |
| លោក Chuan-Hsing Huang | អភិបាលឯករាជ្យ |

## ភាគហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់កាន់កាប់ ឬមានការទាក់ទិននៅក្នុងភាគហ៊ុនផ្ទាល់ ឬដោយប្រយោលរបស់សម្ព័ន្ធធនាគារ និងធនាគារនៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុង និងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានធនាគារជាគូភាគីមួយក្នុងគោលបំណង ជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុននោះទេ ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល (ត)

តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុឆ្នាំកន្លងទៅ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ ដែលបានរួមបញ្ចូល នៅក្នុងចំនួនបរិលាភសរុបទទួលបាន ឬដល់កំណត់ទទួលបាន ដោយសមាជិកក្រុមប្រឹក្សាភិបាលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈកិច្ចសន្យាដែលធ្វើឡើងដោយធនាគារ ឬជាមួយក្រុមហ៊ុនពាក់ព័ន្ធដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅលើរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញភាពពិតនិងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុនិងស្ថានភាពលំហូរ ទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(ក) ប្រកាន់យកគោលនយោបាយគណនេយ្យសមស្របដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយអនុវត្ត គោលនយោបាយទាំងនោះ ប្រកបដោយសង្គតិភាព ។

(ខ) គោរពតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ និងពន្យល់ឲ្យបានច្បាស់លាស់ និងកំណត់បរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ និងការរក្សាទុកបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព ។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម និងបង្ហាញពីបញ្ហាដែលពាក់ព័ន្ធទៅលើការបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃបញ្ជីគណនេយ្យ លុះត្រាតែអ្នកគ្រប់គ្រងមានបំណងជម្រះបញ្ជីផ្អាកដំណើរការរបស់សម្ព័ន្ធធនាគារឬធនាគារ ឬគ្មានជម្រើស សមរម្យដ៏ទៃទៀតក្រៅពីការធ្វើបែបនេះ ។

(ង) ត្រួតពិនិត្យ និងដឹកនាំសម្ព័ន្ធធនាគារ និងធនាគារឲ្យមានប្រសិទ្ធិភាពលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់សម្ព័ន្ធធនាគារ និងធនាគារ ហើយត្រូវធានាថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំង យ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ សម្ព័ន្ធធនាគារ និងធនាគារ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តរាល់តម្រូវការដូចបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំតំណាងឲ្យក្រុមប្រឹក្សាភិបាល សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានបង្ហាញនៅទំព័រទី ១១ ដល់ទី ៩៦ ដែលបានភ្ជាប់មកជាមួយនេះ ថាបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុសម្ព័ន្ធធនាគារ និងធនាគារនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

*ចុះហត្ថលេខាដោយយោងទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលៈ*

Mr. Mao-Chin Chen
*Chairman*

Mr. Chi-Kan Chung
*Chief Executive Office*

Phnom Penh, Kingdom of Cambodia

Date: 6 MAR 2019

# ៧. របាយការណ៍សវនករឯករាជ

## របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះភាគទុនិក
## ធនាគារ សហពាណិជ្ជ ក.អ.

### មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ សហពាណិជ្ជ ក.អ. ហៅកាត់ថា ("ធនាគារ") និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ ដែលតទៅនេះទាំងធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវហៅកាត់ថា ("សម្ព័ន្ធធនាគារ") និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដែលរួមមាន តារាងតុល្យការរួម និងដាច់ដោយឡែកនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ របាយការណ៍លទ្ធផល របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់រួម និងដាច់ដោយឡែក សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សំគាល់ ដែលរួមមានគោលនយោបាយគណនេយ្យ សំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី ១១ ដល់ទី ៩៦ (ហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ") ។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

### មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ ។ យើងខ្ញុំ មានភាពឯករាជ្យពីសម្ព័ន្ធធនាគារ និងធនាគារដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្ម ដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## *ព័ត៌មានផ្សេងៗ*

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី ១ ដល់ទី ៦ និង របាយការណ៍ប្រចាំឆ្នាំរបស់ធនាគារ ដែលរំពឹងថារួចរាល់បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ ។

មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយ យើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអាន ព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត ។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង ។ យើងខ្ញុំ ពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ ។

## *ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច*

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធ នឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុស ជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្មទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើ ពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការសម្ព័ន្ធធនាគារ និងធនាគារ ឬគ្មានជម្រើស សមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់សម្ព័ន្ធ ធនាគារ និងធនាគារ ។

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមាន ការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួម បញ្ចូលមតិសវនកម្មរបស់យើងខ្ញុំ ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែ វាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរក ឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ ការបង្ហាញខុសជាសារវន្ត អាចកើតឡើងដោយសារ ការក្លែងបន្លំ ឬកំហុសឆ្គងហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួម

បញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម ។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់សម្ព័ន្ធធនាគារ និងធនាគារឡើយ ។
- ការវាយតម្លៃលើភាពសមស្រប នៃគោលនយោបាយគណនេយ្យដែលសម្ព័ន្ធធនាគារ និងធនាគារ បានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធ ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង ។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់សារវន្ត ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារ ដើម្បីបន្តនិរន្តរភាពអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ យ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យសម្ព័ន្ធធនាគារ និងធនាគារបញ្ឈប់និរន្តរភាពនៃអាជីវកម្ម ។
- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ ។
- ទទួលបាននូវភស្តុតាងសវនកម្មដែលសមស្រប និង គ្រប់គ្រាន់ ពាក់ព័ន្ធនឹងព័ត៌មានហិរញ្ញវត្ថុសម្រាប់បណ្តាបុត្រសម្ព័ន្ធ នៅក្នុងសម្ព័ន្ធធនាគារដើម្បីបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុរួម ។ យើងខ្ញុំទទួលខុសត្រូវក្នុងការដឹកនាំ ការត្រួតត្រាមើល និងការប្រត្តិបត្តិនៃសវនកម្មរបស់សម្ព័ន្ធធនាគារ ។ យើងខ្ញុំរក្សាការទទួលខុសត្រូវលើមតិសវនកម្មរបស់យើងខ្ញុំ ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀត វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌាចំកាត់**




Nge Huy
*Partner*

Phnom Penh, Kingdom of Cambodia

6 March 2019

# ៨. របាយការណ៍ហិរញ្ញវត្ថុ

## ធនាគារ សហពាណិជ្ជ ក.អ. និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

### តារាងតុល្យការរួម

| | | ២០១៨ | | ២០១៧ | |
|---|---|---|---|---|---|
| | កំណត់សំគាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | | ២៩.១៣២.៣២៤ | ១១៧.០៥៣.៦៧៨ | ២៧.៦៧៤.០៩៦ | ១១១.៧២០.៣២៦ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៥ | ៩៦.៦៦៦.៩៤១ | ៣៨៨.៤០៧.៧៦៩ | ១២២.៦៤៧.៣០៧ | ៤៩៥.១២៧.១៧៨ |
| សមតុល្យនៅធនាគារ និងគ្រឹះស្ថាន ហិរញ្ញវត្ថុផ្សេងៗ | ៦ | ២១.៦៥៩.៨៨០ | ៨៧.០២៩.៣៩៨ | ១៨.៣១២.៨៦៣ | ៧៣.៩២៩.០២៨ |
| ការវិនិយោគសម្រាប់លក់ | | ៣៤០.៩៦៨ | ១.៣៧០.០០៩ | ២៩៧.៧៦៧ | ១.២០២.០៨៥ |
| ឥណទាននិងបុរេប្រទានអតិថិជន | ៧ | ៣១៥.៤២៤.១៩៨ | ១.២៦៧.៣៧៤.៤២៨ | ៣១៦.៤០៨.៦៣៧ | ១.២៧៧.៣៤១.៦៦៨ |
| ភតិសន្យាហិរញ្ញវត្ថុដែលត្រូវទទួល | | ៤.១០៤ | ១៦.៤៩០ | - | - |
| ទ្រព្យនិងបរិក្ខារ | ៨ | ៤១.១០៩.៦២១ | ១៦៥.១៧៨.៤៥៧ | ៣១.៦១៦.៩៤៩ | ១២៧.៦៣៧.៦២៣ |
| ពន្ធពន្យាទ្រព្យសកម្ម | ១៣ (គ) | ៨.០៤០.៨២០ | ៣២.៣០៨.០១៥ | ៩.១៨៦.២៨៤ | ៣៧.០៨៥.០២៩ |
| ទ្រព្យសកម្មអរូបី | ៩ | ៤២១.៨១៥ | ១.៦៩៤.៨៥៣ | ៨៤៣.៥៦៦ | ៣.៤០៥.៤៧៦ |
| ទ្រព្យសកម្មផ្សេងៗ | ១០ | ៤.៩២២.៩១០ | ១៩.៧៨០.២៥២ | ៦.២៧០.៥៣៣ | ២៥.៣១៤.១៤១ |
| **ទ្រព្យសកម្មសរុប** | | ៥១៧.៧២៣.៥៨១ | ២.០៨០.២១៣.៣៤៩ | ៥៣៣.២៥៨.០០២ | ២.១៥២.៧៦២.៥៥៤ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ១១ | ៤.១៥៧.៩៣៤ | ១៦.៧០៦.៥៧៩ | ៥.៩៩៤.១៩៤ | ២៤.១៩៨.៥៦១ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១២ | ៣៣១.០២៥.៦៤១ | ១.៣៣០.០៦១.០២៦ | ២៧៩.៥១២.៥៨០ | ១.១២៨.៣៩២.២៨៥ |
| សំវិធានធនលើសមាសធាតុក្រៅតារាង តុល្យការ | ៧(ខ) | ៣២២.០៨៩ | ១.២៩៤.១៥៤ | - | - |
| ប្រាក់កម្ចី | ១៤ | ៥៣.២៣២.៦៨៩ | ២១៣.៨៨៨.៩៤៤ | ១២២.៥៦៥.៤៤០ | ៤៩៤.៧៩៦.៦៨១ |
| បំណុលបន្ទាប់បន្សំ | ១៥ | ២៩.០០០.០០០ | ១១៦.៥២២.០០០ | ២៩.០០០.០០០ | ១១៧.០៧៣.០០០ |
| កាតព្វកិច្ចសោធននិវត្តន៍បុគ្គលិក | ១៦ | ៤១៦.០២៨ | ១.៦៧១.៦០១ | ២៥៥.៦១៣ | ១.០៣១.៩១០ |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ /បំណុលពន្ធអប្បបរមា | ១៣ (ខ) | ១៧៥.៦៥៦ | ៧០៥.៧៨៦ | ៨២.៨១៩ | ៣៣៤.៣៤០ |
| បំណុលផ្សេងៗ | ១៧ | ២៣.១១៨.៥៨៦ | ៩២.៨៩០.៤៧៨ | ២៣.៦៣៦.៦៩២ | ៩៥.៤២១.៣២៦ |
| **បំណុលសរុប** | | ៤៤១.៤៤៨.៦២៣ | ១.៧៧៣.៧៤០.៥៦៨ | ៤៦១.០៤៧.៣៣៨ | ១.៨៦១.២៤៨.១០៣ |

**នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨**

## ធនាគារ សហពាណិជ្ជ ក.អ. និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

### តារាងតុល្យការរួម (ត)
### នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

| | | ២០១៨ | | ២០១៧ | |
|---|---|---|---|---|---|
| | កំណត់សំគាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| **មូលធនភាគទុនិក** | | | | | |
| ដើមទុន | ១៨ | ៨០.០០០.០០០ | ៣២១.៤៤០.០០០ | ៣៧.៥០០.០០០ | ១៥១.៣៨៧.៥០០ |
| ដើមទុនបន្ថែមពីភាគទុនិក | ១៨ | - | - | ៤២.៥០០.០០០ | ១៧១.៥៧២.៥០០ |
| ប្រាក់ខាតបង្គរ | | (២៩.៥៩៨.៣១៤) | (១១៨.៩២៦.០២៦) | (៣៣.៦២៨.៧២៦) | (១៣៥.៧៥៩.១៦៧) |
| ទុនបម្រុងដែលមិនអាចបែងចែកបាន | | ២៥.៦២២.៧៧២ | ១០២.៩៥២.២៩៨ | ២៥.៦២២.៧៧២ | ១០៣.៤៣៩.១៣១ |
| ទុនបម្រុងលើការវិនិយោគសម្រាប់លក់ | | ២៥០.៥០០ | ១.០០៦.៥០៩ | ២១៦.៦១៨ | ៨៧៤.៤៨៧ |
| **មូលធន សរុប** | | ៧៦.២៧៤.៩៥៨ | ៣០៦.៤៧២.៧៨១ | ៧២.២១០.៦៦៤ | ២៩១.៥១៤.៤៥១ |
| **បំណុល និងមូលធនសរុប** | | ៥១៧.៧២៣.៥៨១ | ២.០៨០.២១៣.៣៤៩ | ៥៣៣.២៥៨.០០២ | ២.១៥២.៧៦២.៥៥៤ |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ធនាគារ សហពាណិជ្ជ ក.អ. និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

### របាយការណ៍លទ្ធផលរួម
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

| | កំណត់សំគាល់ | ២០១៨ | | ២០១៧ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ចំណូលការប្រាក់ | ១៩ | ២៥.៤៣០.១៦០ | ១០២.១៧៨.៣៨៣ | ៣០.២១៩.៧០៧ | ១២១.៩៩៦.៩៥៧ |
| ចំណាយការប្រាក់ | ២០ | (៨.៦៤១.២២៧) | (៣៤.៧២០.៤៥០) | (១៣.១២១.០៣១) | (៥២.៩៦៩.៦០២) |
| **ចំណូលការប្រាក់សុទ្ធ** | | ១៦.៧៨៨.៩៣៣ | ៦៧.៤៥៧.៩៣៣ | ១៧.០៩៨.៦៧៦ | ៦៩.០២៧.៣៥៥ |
| ចំណូលថ្លៃឈ្នួលនិងកម្រៃជើងសារ | ២១ | ៣.៦៣៤.០៤២ | ១៤.៦០១.៥៨១ | ៣.៦៣២.៧៨០ | ១៤.៦៦៥.៥៣៣ |
| ចំណាយថ្លៃឈ្នួលនិងកម្រៃជើងសារ | ២២ | (២.៣៥១.៨១៦) | (៩.៤៤៩.៥៩៧) | (២.៤៨០.៨៤០) | (១០.០១៥.១៥១) |
| **ចំណូលថ្លៃឈ្នួលនិងកម្រៃជើងសារសុទ្ធ** | | ១.២៨២.២២៦ | ៥.១៥១.៩៨៤ | ១.១៥១.៩៤០ | ៤.៦៥០.៣៨២ |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២៣ | ១៤.១៩៤.៣០៩ | ៥៧.០៣២.៧៣៤ | ៤.៩០៤.៦២៩ | ១៩.៧៩៩.៩៨៧ |
| **ចំណូលប្រតិបត្តិការសរុប** | | ៣២.២៦៥.៤៦៨ | ១២៩.៦៤២.៦៥១ | ២៣.១៥៥.២៤៥ | ៩៣.៤៧៧.៧២៤ |
| ចំណាយបុគ្គលិក | ២៤ | (៤.៩២១.១៥១) | (១៩.៧៧៣.១៨៥) | (៦.៥៩១.៦៥៧) | (២៦.៦១០.៥១៩) |
| រំលស់លើទ្រព្យនិងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | ២៥ | (២.១១១.៤២៣) | (៨.៤៨៣.៦៩៨) | (២.២៣៦.៤៦៩) | (៩.០២៨.៦២៥) |
| ចំណាយទូទៅនិងរដ្ឋបាល | ២៦ | (៤.២៥៥.៩៧០) | (១៧.១០០.៤៨៧) | (៦.៨២៦.៧២៧) | (២៧.៥៥៩.៤៩៧) |
| សំវិធានធនលើឥណទានបាត់បង់ | ៧(ក) | (១៤.៨៦៥.៨២១) | (៥៩.៧៣០.៨៦៩) | (៣២.៧៣៤.៤៤៨) | (១៣២.១៤៨.៩៦៧) |
| ចំណាយពន្ធអប្បបរមា | ១៣(ខ) | (៤២៣.៩៨២) | (១.៧០៣.៥៦០) | (៣៨៧.៤៨០) | (១.៥៦៤.២៥៧) |
| **ចំណេញ/(ខាត)មុនបង់ពន្ធលើប្រាក់ចំណេញ** | | ៥.៦៨៧.១២១ | ២២.៨៥០.៨៥២ | (២៥.៦២១.៥៣៦) | (១០៣.៤៣៤.១៤១) |
| ចំណេញ/(ឥណទាន)ពន្ធលើ ប្រាក់ចំណេញ | ១៣(ខ) | (១.៣១៦.០០៤) | (៥.២៨៧.៧០៤) | ៥.២៨០.២៧១ | ២១.៣១៦.៤៥៤ |
| **ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ** | | ៤.៣៧១.១១៧ | ១៧.៥៦៣.១៤៨ | (២០.៣៤១.២៦៥) | (៨២.១១៧.៦៨៧) |
| **ត្រូវបែងចែកជូន៖** | | | | | |
| ភាគទុនិករបស់ធនាគារ | | ៤.០៣០.៤១២ | ១៦.១៩៩.១៩៥ | (២០.៣០៩.៥៤៧) | (៨១.៩៨៩.៦៤១) |
| ភាគហ៊ុនអប្បភាគ | | ៣៤០.៧០៥ | ១.៣៦៨.៩៥៣ | (៣១.៧១៨) | (១២៨.០៤៦) |
| | | ៤.៣៧១.១១៧ | ១៧.៥៦៣.១៤៨ | (២០.៣៤១.២៦៥) | (៨២.១១៧.៦៨៧) |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ធនាគារ សហពាណិជ្ជ ក.អ. និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

### របាយការណ៍ស្តីពីបម្រែបម្រួលមូលធនរួម
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

| | ដើមទុន ដុល្លារអាមេរិក | ដើមទុនបន្ថែមពីភាគទុនិក ដុល្លារអាមេរិក | ប្រាក់ខាតបង្គរទុក ដុល្លារអាមេរិក | ទុនបម្រុងដែលមិនអាចបែងចែកបាន ដុល្លារអាមេរិក | ទុនបម្រុងលើការវិនិយោគសម្រាប់លក់ ដុល្លារអាមេរិក | សរុ ដុល្លារអ |
|---|---|---|---|---|---|---|
| **សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨** | | | | | | |
| សមតុល្យនាថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៨ | ៣៧.៥០០.០០០ | ៤២.៥០០.០០០ | (៣៣.៦២៨.៧២៦) | ២៥.៦២២.៧៧២ | ២១៦.៦១៨ | ៧២.២ |
| ទុនបន្ថែម | ៤២.៥០០.០០០ | (៤២.៥០០.០០០) | - | - | - | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | ៤.០៣០.៤១២ | - | - | ៤.០ |
| ចំណេញពីវិនិយោគសម្រាប់លក់ដែលមិនទាន់ទទួលបាន | - | - | - | - | ៣៣.៨៨២ | ៣ |
| **សមតុល្យនាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨** | ៨០.០០០.០០០ | - | (២៩.៥៩៨.៣១៤) | ២៥.៦២២.៧៧២ | ២៥០.៥០០ | ៧៦.២ |
| សមមូលនឹងពាន់រៀល –(កំណត់សំគាល់ ៤) | ៣២១.៤៤០.០០០ | - | (១១៨.៩២៦.០២៦) | ១០២.៩៥២.២៩៨ | ១.០០៦.៥០៩ | ៣០៦.៤ |
| **សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧** | | | | | | |
| សមតុល្យនាថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៧ | ៣៧.៥០០.០០០ | - | (១៣.៣១៩.១៧៩) | ២៥.៦២២.៧៧២ | ១៤១.៥៨១ | ៤៩.៩ |
| ដើមទុនបុរេប្រទាន | - | ៤២.៥០០.០០០ | - | - | - | ៤២.៥ |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | (២០.៣០៩.៥៤៧) | - | - | (២០.៣០ |
| ចំណេញពីវិនិយោគសម្រាប់លក់ដែលមិនទាន់ទទួលបាន | - | - | - | - | ៧៥.០៣៧ | ៧ |
| **សមតុល្យនាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧** | ៣៧.៥០០.០០០ | ៤២.៥០០.០០០ | (៣៣.៦២៨.៧២៦) | ២៥.៦២២.៧៧២ | ២១៦.៦១៨ | ៧២.២ |
| សមមូលនឹងពាន់រៀល –(កំណត់សំគាល់ ៤) | ១៥១.៣៨៧.៥០០ | ១៧១.៥៧២.៥០០ | (១៣៥.៧៥៩.១៦៧) | ១០៣.៤៣៩.១៣១ | ៨៧៤.៤៨៧ | ២៩១.៥ |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ធនាគារ សហពាណិជ្ជ ក.អ. និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

### របាយការណ៍លំហូរទឹកប្រាក់រួម
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

| | | ២០១៨ | | ២០១៧ | |
|---|---|---|---|---|---|
| | កំណត់សំគាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញ/(ខាត)មុនបង់ពន្ធលើប្រាក់ចំណេញ | | ៥.៦៨៧.១២១ | ២២.៨៥០.៨៥២ | (២៥.៦២១.៥៣៦) | (១០៣.៤៣៤.១ |
| និយ័តភាពលើ៖ | | | | | |
| រំលស់ទ្រព្យនិងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | ២៥ | ២.១១១.៤២៣ | ៨.៤៨៣.៦៩៨ | ២.២៣៦.៥៦៩ | ៩.០២៨.៦ |
| ចំណាយពន្ធអប្បបរមា | | ៤២៣.៩៨២ | ១.៧០៣.៥៦០ | ៣៨៧.៤៨០ | ១.៥៦៤.២ |
| ចំណូលការប្រាក់សុទ្ធ | | (១៦.៧៨៨.៩៣៣) | (៦៧.៤៥៧.៩៣៣) | (១៧.០៩៨.៦៧៦) | (៦៩.០២៧.៣ |
| សំវិធានធនលើឥណទានបាត់បង់ | ៧(ក) | ១៤.៣៣៣.២៩៤ | ៥៧.៥៩១.១៧៥ | ៣២.៧៣៤.៤៤៨ | ១៣២.១៤៨.៩ |
| សំវិធានធនជាមួយធនាគារផ្សេងទៀតនិង គ្រឹះស្ថានហិរញ្ញវត្ថុ | | ២១០.៤៣៨ | ៨៤៥.៥៤០ | - | |
| សំវិធានធនលើកិច្ចសន្យាក្រៅតុល្យការ | | ៣២២.០៨៩ | ១.២៩៤.១៥៤ | - | |
| កាតព្វកិច្ចសោធននិវត្តន៍បុគ្គលិក | | ១៨៨.៧២៩ | ៧៥៨.៣១៣ | ១.៧៤០.០០០ | ៧.០២៤.៣ |
| ភាគលាភពីការវិនិយោគសម្រាប់លក់ | | (៩.៣១៩) | (៣៧.៤៤៤) | - | |
| ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ | | (១.០៦៩.៨៩៦) | (៤.២៩៨.៨៤២) | (១៣.០១២) | (៥២.៥ |
| | | ៥.៤០៨.៩២៨ | ២១.៧៣៣.០៧៣ | (៥.៦៣៤.៨២៧) | (២២.៧៤៧.៧ |
| បម្រែបម្រួលនៃ៖ | | | | | |
| ប្រាក់តម្កល់តាមច្បាប់នៅធនាគារជាតិនៃកម្ពុជា | | ៣.៧៩១.៦៥៨ | ១៥.២៣៤.៨៨២ | (៥០៤.៤៩៦) | (២.០៣៦.៦ |
| ឥណទាន និងបុរេប្រទានអតិថិជន | | (១៣.៣៤៨.៨៥៥) | (៥៣.៦៣៥.៦៩៩) | ៤៤.៩១១.៥១២ | ១៨១.៣០៧.៣ |
| ទ្រព្យសកម្មផ្សេងៗ | | ១.១៨៦.២៧៧ | ៤.៧៦៦.៥៦១ | ៥៤៩.៩២២ | ២.២២០.០ |
| ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | | (១.៨៣៦.២៦០) | (៧.៣៧៨.០៩៣) | ២.៦៨៥.៥៦៤ | ១០.៨៤១.៦ |
| ប្រាក់បញ្ញើរបស់អតិថិជន | | ៥១.៥១៣.០៦១ | ២០៦.៩៧៩.៤៧៩ | (១០៤.១៥៩.០៩៧) | (៤២០.៤៩០.២ |
| បំណុលផ្សេងៗ | | (៤៦៧.៥០១) | (១.៨៧៨.៤១៩) | ១៥.៣៧៥.៥៦២ | ៦២.០៧១.១ |
| **សាច់ប្រាក់ទទួលបានពី/(ប្រើប្រាស់ក្នុង)ប្រតិបត្តិការ** | | ៤៦.២៤៧.៣០៨ | ១៨៥.៨២១.៦៨៤ | (៤៦.៧៧៥.៩៦០) | (១៨៨.៨៣៤.៥ |
| កាតព្វកិច្ចសោធននិវត្តន៍បុគ្គលិកបានបង់ | | (២៨.៣១៤) | (១១៣.៧៦៦) | (១.៧៨៧.៨៦៣) | (៧.២១៧.៦ |
| ចំណូលការប្រាក់បានទទួល | | ២៥.៥២៤.៨៧៣ | ១០២.៥៥៨.៩៤០ | ៣០.៥៩៤.៩៤៩ | ១២៣.៥០៩.៧ |
| ចំណាយការប្រាក់បានបង់ | | (៩.០៣២.៥៣៧) | (៣៦.២៩២.៧៣៤) | (១៧.៩៨៧.៨៩៤) | (៧២.៦១៧.១ |
| ពន្ធលើប្រាក់ចំណេញបានបង់ | ១៣(ខ) | (១៦.០៤៥) | (៦៤.៤៦៩) | (១១១.៨៥១) | (៤៥១.៥ |
| ពន្ធអប្បបរមាបានបង់ | ១៣(ខ) | (៤២៣.១១១) | (១.៧០០.០៦០) | (៣៥១.២៦៨) | (១.៤១៨.០ |
| **សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើប្រាស់ក្នុង)សកម្មភាពប្រតិបត្តិការ** | | ៦២.២៧២.១៧៤ | ២៥០.២០៩.៥៩៥ | (៣៦.៤២០.៣៨៧) | (១៤៧.០២៩.១ |

## ធនាគារ សហពាណិជ្ជ ក.អ. និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

### របាយការណ៍លំហូរទឹកប្រាក់រួម (ត)
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

| | កំណត់សំគាល់ | ២០១៨ ដុល្លារអាមេរិក | ២០១៨ ពាន់រៀល (កំណត់សំគាល់ ៤) | ២០១៧ ដុល្លារអាមេរិក | ២០១៧ ពាន់រៀល (កំណត់សំគាល់ ៤) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| សមតុល្យនៅធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | | - | - | ៤.០០០.០០០ | ១៦.១៤៨.០០០ |
| សាច់ប្រាក់បានពីការលក់ទ្រព្យនិងបរិក្ខារ | | ១.៨៦៦.៥២៤ | ៧.៤៩៩.២៩២ | ២៨.១៩៣ | ១១៣.៨១៥ |
| ការទិញទ្រព្យនិងបរិក្ខារ | | (១១.៩៤៩.៣១៩) | (៤៨.០១២.៣៦៤) | (៨.០៧៦.៦៧១) | (៣២.៦០៥.៥២១) |
| ការទិញទ្រព្យសកម្មអរូបី | | (២៩.៥៥៣) | (១១៨.៧៤៤) | (១៦.៦៥៩) | (៦៧.២៥២) |
| សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | | (១០.១១២.៤៤៨) | (៤០.៦៣១.៨១៦) | (៤.០៦៥.១៣៧) | (១៦.៤១០.៩៥៨) |
| **លំហូរទឹកប្រាក់ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ដើមទុនបន្ថែមពីភាគទុនិក | | - | - | ៤២.៥០០.០០០ | ១៧១.៥៧២.៥០០ |
| ការទូទាត់សងប្រាក់កម្ចី | | (១១៨.៣៤៣.៨៧៥) | (៤៧៥.៥០៥.៦៩០) | (៦៨១.២០៨) | (២.៧៥០.០៣៧) |
| សាច់ប្រាក់បានពីប្រាក់កម្ចី និងអនុបំណុល | | ៤៩.០១១.១២៤ | ១៩៦.៩២៦.៦៩៦ | - | - |
| **លំហូរទឹកប្រាក់(ប្រើប្រាស់ក្នុង)ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | (៦៩.៣៣២.៧៥១) | (២៧៨.៥៧៨.៩៩៤) | ៤១.៨១៨.៧៩២ | ១៦៨.៨២២.៤៦៣ |
| **ការ(ថយចុះ)កើនឡើងសាច់ប្រាក់និងសាច់ប្រាក់សមមូលសុទ្ធ** | | (១៧.១៧៣.០២៥) | (៦៩.០០១.២១៥) | ១.៣៣៣.២៦៨ | ៥.៣៨២.៤០៤ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ** | | ៩៨.៤៥៨.៦៤៥ | ៣៩៧.៤៧៧.៥៥១ | ៩៧.១២៥.៣៧៧ | ៣៩២.០៩៥.១៤៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១.៨៧០.៧១៤) | - | - |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ២៧ | ៨១.២៨៥.៦២០ | ៣២៦.៦០៥.៦២២ | ៩៨.៤៥៨.៦៤៥ | ៣៩៧.៤៧៧.៥៥១ |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ធនាគារ សហពាណិជ្ជ ក.អ.

### តារាងតុល្យការដាច់ដោយឡែក
### នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

| | កំណត់សំគាល់ | ២០១៨ ដុល្លារអាមេរិក | ២០១៨ ពាន់រៀល (កំណត់សំគាល់ ៤) | ២០១៧ ដុល្លារអាមេរិក | ២០១៧ ពាន់រៀល (កំណត់សំគាល់ ៤) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | | ២៩.១៣២.៣២៤ | ១១៧.០៥៣.៦៧៨ | ២៧.៦៧៤.០៩៦ | ១១១.៧២០.៣២៦ |
| សមតុល្យនៅធនាគារធនាគារជាតិនៃកម្ពុជា | ៥ | ៩៦.៦៦៦.៩៤១ | ៣៨៨.៤០៧.៧៦៩ | ១២២.៦៤៧.៣០៧ | ៤៩៥.១២៧.១៧៨ |
| សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ៦ | ២០.៨៣៣.៤១១ | ៨៣.៧០៨.៦៤៥ | ១៨.០៣៤.៥៣៥ | ៧២.៨០៥.៤១៨ |
| វិនិយោគសម្រាប់លក់ | | ៣៤០.៩៦៨ | ១.៣៧០.០០៩ | ២៩៧.៧៦៧ | ១.២០២.០៨៥ |
| ឥណទាននិងបុរេប្រទានអតិថិជន | ៧ | ៣១៥.៤២៤.១៩៨ | ១.២៦៧.៣៧៤.៤២៨ | ៣១៦.៤០៨.៦៣៧ | ១.២៧៧.៣៤១.៦៦៨ |
| វិនិយោគក្រុមហ៊ុនបុត្រសម្ព័ន្ធ | | ៤៩០ | ១.៩៦៩ | ៤៩០ | ១.៩៧៨ |
| ទ្រព្យនិងបរិក្ខារ | ៨ | ៣១.៩៣៨.៤៤៥ | ១២៨.៣២៨.៦៧៣ | ២២.៦៥៤.៥៩៥ | ៩១.៤៥៦.៦០០ |
| ពន្ធពន្យាទ្រព្យសកម្ម | ១៣ (គ) | ៨.០៣៨.៩៨២ | ៣២.៣០០.៦៣០ | ៩.១៥៥.៣៥៥ | ៣៦.៩៦០.១៦៨ |
| ទ្រព្យសកម្មអរូបី | ៩ | ៤២១.១៧១ | ១.៦៩២.២៦៥ | ៨៤២.៧០៨ | ៣.៤០២.០១២ |
| ទ្រព្យសកម្មផ្សេងៗ | ១០ | ៤.៩១៨.០៥៥ | ១៩.៧៦០.៧៤៥ | ៥.២៦៩.៣៣៣ | ២១.២៧២.២៩៨ |
| **ទ្រព្យសកម្មសរុប** | | ៥០៧.៧១៤.៩៨៥ | ២.០៣៩.៩៩៨.៨១១ | ៥២២.៩៨៤.៨២៣ | ២.១១១.២៨៩.៧៣១ |
| **បំណុល និងមូលធនភាគទុនិក** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ១១ | ៤.១៥៧.៩៣៤ | ១៦.៧០៦.៥៧៩ | ៥.៩៩៤.១៩៤ | ២៤.១៩៨.៥៦១ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១២ | ៣៣៣.២៦៣.២៥០ | ១.៣៣៩.០៥១.៧៣៩ | ២៨០.៤៨១.០៨៤ | ១.១៣២.៣០២.១៣៦ |
| សំវិធានធនលើកិច្ចសន្យាក្រៅតារាងតុល្យការ | ៧ (ក) | ៣២២.០៨៩ | ១.២៩៤.១៥៤ | - | - |
| ប្រាក់កម្ចី | ១៤ | ៤១.២០៥.៨៨២ | ១៦៥.៥៦៥.២៣៤ | ១១០.៥៤៩.៧៥៧ | ៤៤៦.២៨៩.៣៦៩ |
| បំណុលបន្ទាប់បន្សំ | ១៥ | ២៩.០០០.០០០ | ១១៦.៥២២.០០០ | ២៩.០០០.០០០ | ១១៧.០៧៣.០០០ |
| បំណុលភតិសន្យាហិរញ្ញប្បទាន | | ៩៦៨.៧៤៣ | ៣.៨៩២.៤០៩ | ១.០៣០.៧៥៥ | ៤.១៦១.១៥៨ |
| កាតព្វកិច្ចសោធននិវត្តន៍បុគ្គលិក | ១៦ | ៤១៦.០២៨ | ១.៦៧១.៦០១ | ២៥៥.៦១៣ | ១.០៣១.៩១០ |
| បំណុលពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ/បំណុលពន្ធអប្បបរមា | ១៣(ខ) | ៣៧.០៨៣ | ១៤៨.៩៩៩ | ៣៦.២១២ | ១៤៦.១៨៨ |
| បំណុលផ្សេងៗ | ១៧ | ២២.៦៧៣.០៩៥ | ៩១.១០០.៤៩៦ | ២៣.៧០៣.២៧៧ | ៩៥.៦៩០.១២៩ |
| **បំណុលសរុប** | | ៤៣២.០៤៤.១០៤ | ១.៧៣៥.៩៥៣.២១១ | ៤៥១.០៥០.៨៩២ | ១.៨២០.៨៩២.៤៥១ |
| **មូលធនភាគទុនិក** | | | | | |
| ដើមទុន | ១៨ | ៨០.០០០.០០០ | ៣២១.៤៤០.០០០ | ៣៧.៥០០.០០០ | ១៥១.៣៨៧.៥០០ |
| ដើមទុនបន្ថែមពីភាគទុនិក | ១៨ | - | - | ៤២.៥០០.០០០ | ១៧១.៥៧២.៥០០ |
| ប្រាក់ខាតបង្គរ | | (៣០.២០២.៣៩១) | (១២១.៣៥៣.២០៧) | (៣៣.៩០៥.៤៥៩) | (១៣៦.៨៧៦.៣៣៨) |
| ទុនបម្រុងដែលមិនអាចបែងចែកបាន | | ២៥.៦២២.៧៧២ | ១០២.៩៥២.២៩៨ | ២៥.៦២២.៧៧២ | ១០៣.៤៣៩.១៣១ |
| ទុនបម្រុងលើការវិនិយោគសម្រាប់លក់ | | ២៥០.៥០០ | ១.០០៦.៥០៩ | ២១៦.៦១៨ | ៨៧៤.៤៨៧ |
| **មូលធនភាគទុនិកសរុប** | | ៧៥.៦៧០.៨៨១ | ៣០៤.០៤៥.៦០០ | ៧១.៩៣៣.៩៣១ | ២៩០.៣៩៧.២៨០ |
| **បំណុល និងមូលធនភាគទុនិកសរុប** | | ៥០៧.៧១៤.៩៨៥ | ២.០៣៩.៩៩៨.៨១១ | ៥២២.៩៨៤.៨២៣ | ២.១១១.២៨៩.៧៣១ |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ធនាគារ សហពាណិជ្ជ ក.អ.

# របាយការណ៍លទ្ធផលដាច់ដោយឡែក
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

| | កំណត់សំគាល់ | ២០១៨ ដុល្លារអាមេរិក | ២០១៨ ពាន់រៀល (កំណត់សំគាល់ ៤) | ២០១៧ ដុល្លារអាមេរិក | ២០១៧ ពាន់រៀល (កំណត់សំគាល់ ៤) |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | ១៩ | ២៥.៣៤៩.០២៨ | ១០១.៨៥២.៣៩៥ | ៣០.១២៤.៥៨៥ | ១២១.៦១២.៩៥០ |
| ចំណាយការប្រាក់ | ២០ | (៨.០៧១.៣៨៨) | (៣២.៤៣០.៨៣៧) | (១២.៦៥៦.៧៥៧) | (៥១.០៩៥.៣២៨) |
| **ចំណូលការប្រាក់សុទ្ធ** | | ១៧.២៧៧.៦៤០ | ៦៩.៤២១.៥៥៨ | ១៧.៤៦៧.៨២៨ | ៧០.៥១៧.៦២២ |
| ចំណូលថ្លៃឈ្នួលនិងកម្រៃជើងសារ | ២១ | ៣.៦៣៤.០៤២ | ១៤.៦០១.៥៨១ | ៣.៦៣២.៧៨០ | ១៤.៦៦៥.៥៣៣ |
| ចំណាយថ្លៃឈ្នួលនិងកម្រៃជើងសារ | ២២ | (២.៣៥១.៨១៦) | (៩.៤៤៩.៥៩៧) | (២.៤៨០.៨៤០) | (១០.០១៥.១៥១) |
| **ចំណូលថ្លៃឈ្នួលនិងកម្រៃជើងសារសុទ្ធ** | | ១.២៨២.២២៦ | ៥.១៥១.៩៨៤ | ១.១៥១.៩៤០ | ៤.៦៥០.៣៨២ |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២៣ | ១៣.៤១៥.១៥៦ | ៥៣.៩០២.០៩៧ | ៤.៩៩០.៦៥១ | ២០.១៤៧.២៥៨ |
| **ចំណូលប្រតិបត្តិការសរុប** | | ៣១.៩៧៥.០២២ | ១២៨.៤៧៥.៦៣៩ | ២៣.៦១០.៤១៩ | ៩៥.៣១៥.២៦២ |
| ចំណាយបុគ្គលិក | ២៤ | (៤.៩១៥.១៤១) | (១៩.៧៤៩.០៣៧) | (៦.៥៩១.៦៥៧) | (២៦.៦១០.៥១៩) |
| រំលស់ទ្រព្យនិងបរិក្ខារនិង រំលស់ទ្រព្យសកម្មអរូបី | ២៥ | (២.០៧១.៤៣១) | (៨.៣២៣.០១០) | (២.១៩៧.៣៧៤) | (៨.៨៧០.៧៩៩) |
| ចំណាយទូទៅនិងរដ្ឋបាល | ២៦ | (៤.៨៧៩.២០៦) | (១៩.៦០៤.៦៥០) | (៧.២៩៤.០៤៩) | (២៩.៤៩៦.០៧៦) |
| សំវិធានធនលើឥណទានបាត់បង់ | ៧(ក) | (១៤.៨៦៥.៨២១) | (៥៩.៧៣០.៨៦៩) | (៣២.៧៣៤.៤៤៨) | (១៣២.១៤៨.៩៦៧) |
| ចំណាយពន្ធអប្បបរមា | ១៣(ខ) | (៤២៣.៩៨២) | (១.៧០៣.៥៦០) | (៣៨៧.៤៨០) | (១.៥៦៤.២៥៧) |
| **ចំណេញ/(ខាត)មុនបង់ពន្ធលើប្រាក់ចំណេញ** | | ៤.៨១៩.៤៤១ | ១៩.៣៦៤.៥១៣ | (២៥.៥៩៤.៥៨៩) | (១០៣.៣៧៥.៣៥៦) |
| ចំណេញ/(ឥណទាន)ពន្ធលើ ប្រាក់ចំណេញ | ១៣(ខ) | (១.១១៦.៣៧៣) | (៤.៤៨៥.៥៨៧) | ៥.៣១៥.៥១៧ | ២១.៤៥៨.៧៤២ |
| **ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ** | | ៣.៧០៣.០៦៨ | ១៤.៨៧៨.៩២៦ | (២០.២៧៩.០៧២) | (៨១.៩១៦.៦១៤) |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ធនាគារ សហពាណិជ្ជ ក.អ.

### របាយការណ៍ស្តីពីបម្រែបម្រួលមូលធនដាច់ដោយឡែក
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

| | ដើមទុន ដុល្លារអាមេរិក | ដើមទុនបន្ថែមពីភាគទុនិក ដុល្លារអាមេរិក | ប្រាក់ខាត បង្គរ ដុល្លារអាមេរិក | ទុនបម្រុង ដែលមិនអាចបែងចែកបាន ដុល្លារអាមេរិក | ទុនបម្រុងលើ ការវិនិយោគសម្រាប់លក់ ដុល្លារអាមេរិក | ស ដុល្លារអ |
|---|---|---|---|---|---|---|
| **សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨** | | | | | | |
| សមតុល្យនាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ | ៣៧.៥០០.០០០ | ៤២.៥០០.០០០ | (៣៣.៩០៥.៤៥៩) | ២៥.៦២២.៧៧២ | ២១៦.៦១៨ | ៧១.៩៣ |
| ទុនបន្ថែម | ៤២.៥០០.០០០ | (៤២.៥០០.០០០) | - | - | - | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | ៣.៧០៣.០៦៨ | - | - | ៣.៧( |
| ចំណេញពីវិនិយោគសម្រាប់លក់ដែលមិនទាន់ទទួលបាន | - | - | - | - | ៣៣.៨៨២ | ( |
| **សមតុល្យនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨** | ៨០.០០០.០០០ | - | (៣០.២០២.៣៩១) | ២៥.៦២២.៧៧២ | ២៥០.៥០០ | ៧៥.៦ |
| សមមូលនឹងពាន់រៀល –(កំណត់សំគាល់ ៤) | ៣២១.៤៤០.០០០ | - | (១២១.៣៥៣.២០៧) | ១០២.៩៥២.២៩៨ | ១.០០៦.៥០៩ | ៣០៤.០ |
| **សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧** | | | | | | |
| សមតុល្យនាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៧ | ៣៧.៥០០.០០០ | - | (១៣.៦២៦.៣៨៧) | ២៥.៦២២.៧៧២ | ១៩៤.៥៨១ | ៤៩.៦( |
| ដើមទុនបុរេប្រទាន | - | ៤២.៥០០.០០០ | - | - | - | ៤២.៥ |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | (២០.២៧៩.០៧២) | - | - | (២០.២៧ |
| ចំណេញពីវិនិយោគសម្រាប់លក់ដែលមិនទាន់ទទួលបាន | - | - | - | - | ៧៥.០៣៧ | ( |
| **សមតុល្យនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧** | ៣៧.៥០០.០០០ | ៤២.៥០០.០០០ | (៣៣.៩០៥.៤៥៩) | ២៥.៦២២.៧៧២ | ២១៦.៦១៨ | ៧១.៩៣ |
| សមមូលនឹងពាន់រៀល –(កំណត់សំគាល់ ៤) | ១៥១.៣៨៧.៥០០ | ១៧១.៥៧២.៥០០ | (១៣៦.៨៧៦.៣៣៨) | ១០៣.៤៣៩.១៣១ | ៨៧៤.៤៨៧ | ២៩០.៣ |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ធនាគារ សហពាណិជ្ជ ក.អ.

## របាយការណ៍លំហូរទឹកប្រាក់ដាច់ដោយឡែក
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

| | កំណត់សំគាល់ | ២០១៨ ដុល្លារអាមេរិក | ២០១៨ ពាន់រៀល (កំណត់សំគាល់ ៤) | ២០១៧ ដុល្លារអាមេរិក | ២០១៧ ពាន់រៀល (កំណត់សំគាល់ ៤) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញ/(ខាត)មុនបង់ពន្ធលើប្រាក់ចំណេញ | | ៤.៨១៩.៩៤១ | ១៩.៣៦៤.៥១៣ | (២៥.៥៩៤.៥៨៩) | (១០៣.៣២៥.៣៥៦) |
| និយ័តកម្មលើ៖ | | | | | |
| រំលស់ទ្រព្យនិងបរិក្ខារ | | | | | |
| និងរំលស់ទ្រព្យសកម្មអរូបី | ២៥ | ២.០៧១.៤៣១ | ៨.៣២៣.០១០ | ២.១៩៧.៣៧៤ | ៨.៨៧០.៧៩៩ |
| ចំណាយពន្ធអប្បបរមា | | ៤២៣.៩៨២ | ១.៧០៣.៥៦០ | ៣៨៧.៤៨០ | ១.៥៦៤.២៥៧ |
| ចំណូលការប្រាក់សុទ្ធ | | (១៧.២៧៧.៦៤០) | (៦៩.៤២១.៥៥៨) | (១៧.៤៦៧.៨២៨) | (៧០.៥១៧.៦២២) |
| សំវិធានធនលើឥណទានបាត់បង់ | ៧(ក) | ១៤.៣៣៣.២៩៤ | ៥៧.៥៩១.១៧៥ | ៣២.៧៣៤.៤៤៨ | ១៣២.១៤៨.៩៦៧ |
| សំវិធានធនលើជាមួយធនាគារផ្សេងទៀត | | | | | |
| និងគ្រឹះស្ថានហិរញ្ញវត្ថុ | | ២១០.៤៣៨ | ៨៤៥.៥៤០ | - | - |
| សំវិធានធនលើកិច្ចសន្យាក្រៅតុល្យការ | | ៣២២.០៨៩ | ១.២៩៤.១៥៤ | - | - |
| កាតព្វកិច្ចសោធននិវត្តន៍បុគ្គលិក | | ១៨៨.៧២៩ | ៧៥៨.៣១៣ | ១.៧៤០.០០០ | ៧.០២៤.៣៨០ |
| ភាគលាភពីការវិនិយោគសម្រាប់លក់ | | (៩.៣១៩) | (៣៧.៤៤៤) | - | - |
| ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ | | (១៤៦.៨៦៣) | (៥៩០.០៩៦) | (១៣.០១២) | (៥២.៥២៩) |
| | | ៤.៩៣៥.៥៨២ | ១៩.៨៣១.១៦៧ | (៦.០១៦.១២៧) | (២៤.២៨៧.១០៤) |
| បម្រែបម្រួលនៃ៖ | | | | | |
| ប្រាក់តម្កល់តាមច្បាប់នៅធនាគារជាតិនៃកម្ពុជា | | ៣.៧៩១.៦៥៨ | ១៥.២៣៤.៨៨២ | (៥០៤.៤៩៦) | (២.០៣៦.៦៥០) |
| ឥណទាននិងបុរេប្រទានអតិថិជន | | (១៣.៣៩៨.៨៥៥) | (៥៣.៦៣៥.៦៩៩) | ៤៤.៩១១.៤១២ | ១៨១.៣០៧.៣៧០ |
| ទ្រព្យសកម្មផ្សេងៗ | | ២៥៤.៣១០ | ១.០២១.៨១៨ | ៥៤៩.៩២២ | ២.២២០.០៣៥ |
| ប្រាក់បញ្ញើរបស់ធនាគារ | | | | | |
| និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | | (១.៨៣៦.២៦០) | (៧.៣៧៨.០៩៣) | ២.៦៨៥.៥៦៤ | ១០.៨៤១.៦២២ |
| ប្រាក់បញ្ញើរបស់អតិថិជន | | ៥២.៧៨២.១៦៦ | ២១២.០៧៨.៧៤៣ | (១០៤.៤៨៣.៩៧៥) | (៤២១.៨០១.៨០៧) |
| បំណុលផ្សេងៗ | | (៦៣៨.៨៧២) | (២.៥៦៦.៩៨៨) | ១៥.៣៨២.៥១៧ | ៦២.០៩៩.២២៣ |
| **សាច់ប្រាក់បានប្រើប្រាស់ក្នុងប្រតិបត្តិការ** | | ៤៥.៩៣៩.៧២៩ | ១៨៤.៥៨៥.៨៣០ | (៤៧.៤៧៥.១៨៣) | (១៩១.៦៥៧.៣១១) |
| កាតព្វកិច្ចសោធននិវត្តន៍បុគ្គលិកបានបង់ | | (២៨.៣១៤) | (១១៣.៧៦៦) | (១.៧៨៧.៨៦៣) | (៧.២១៧.៦០៣) |
| ចំណូលការប្រាក់បានទទួល | | ២៥.៤៤៥.៩៩៦ | ១០២.២៤២.០១២ | ៣០.៥០០.៥២៧ | ១២៣.១៣០.៦២៧ |
| ចំណាយការប្រាក់បានបង់ | | (៨.៤៦២.៦៩៨) | (៣៤.០០៣.១២១) | (១៧.៥០៨.៨៦៦) | (៧០.៦៨៣.២៩២) |
| ពន្ធលើប្រាក់ចំនេញបានបង់ | ១៣(ខ) | - | - | (៥៨.៧៥១) | (២៣៧.១៧៨) |
| ពន្ធអប្បបរមាបានបង់ | ១៣(ខ) | (៤២៣.១១១) | (១.៧០០.០៦០) | (៣៥១.២៦៨) | (១.៤១៨.០៦៩) |
| **សាច់ប្រាក់សុទ្ធបានប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | | ៦២.៤៧១.៦០២ | ២៥១.០១០.៨៩៥ | (៣៦.៦៨១.៤០៤) | (១៤៨.០៨២.៨២៦) |

## ធនាគារ សហពាណិជ្ជ ក.អ.

### របាយការណ៍លំហូរទឹកប្រាក់ដាច់ដោយឡែក (ត)
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

| | កំណត់សំគាល់ | ២០១៨ ដុល្លារអាមេរិក | ២០១៨ ពាន់រៀល (កំណត់សំគាល់ ៤) | ២០១៧ ដុល្លារអាមេរិក | ២០១៧ ពាន់រៀល (កំណត់សំគាល់ ៤) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| សមតុល្យនៅធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | | - | - | ៤.០០០.០០០ | ១៦.១៩៨.០០០ |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យនិងបរិក្ខារ | | ១៩១.៩៩១ | ៧៧១.៤២០ | ២៨.១៩៣ | ១១៣.៨១៥ |
| ការទិញទ្រព្យនិងបរិក្ខារ | | (១០.៩៤៩.៣១៩) | (៤៣.៩៩៤.៣៦៤) | (៨.០៧៦.៦៧១) | (៣២.៦០៥.៥២១) |
| ការទិញទ្រព្យសកម្មអរូបី | | (២៩.៥៥៣) | (១១៨.៧៤៤) | (១៥.៨០១) | (៦៣.៧៨៩) |
| ភាគលាភពីការវិនិយោគសម្រាប់លក់ | | (១០.៧៨៦.៨៨១) | (៤៣.៣៩១.៦៨៨) | - | - |
| សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | | (១០.៧៨៦.៨៨១) | (៥៣.៣៩១.៦៨៨) | (៤.០៦៤.២៧៩) | (១៦.៤០៧.៤៩៥) |
| **លំហូរទឹកប្រាក់បានពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ដើមទុនបន្ថែមពីភាគទុនិក | | - | - | ៤២.៥០០.០០០ | ១៧១.៥៧២.៥០០ |
| ការទូទាត់ប្រាក់កម្ចី | | (១១៨.៣៤៣.៨៧៥) | (៤៧៥.៥០៥.៦៩០) | (៦៩៦.៨៩១) | (២.៨១៣.៣៤៩) |
| ការទូទាត់បំណុលភតិសន្យាហិរញ្ញវត្ថុ | | (៦២.០១២) | (២៤៩.១៦៤) | (១.៤៣២) | (៥.៧៨១) |
| សាច់ប្រាក់បានពីប្រាក់កម្ចី និងអនុបំណុល | | ៤៩.០០០.០០០ | ១៩៦.៨៨២.០០០ | - | - |
| **លំហូរទឹកប្រាក់(ប្រើប្រាស់ក្នុង)/ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | (៦៩.៤០៥.៨៨៧) | (២៧៨.៨៧២.៨៥៤) | ៤១.៨០១.៦៧៧ | ១៦៨.៧៥៣.៣៧០ |
| **ការ(ថយចុះ)/កើនឡើងសាច់ប្រាក់និងសាច់ប្រាក់សមមូលសុទ្ធ** | | (១៧.៧២១.១៦៦) | (៧១.២០៣.៦៤៧) | ១.០៥៥.៩៩៤ | ៤.២៦៣.០៤៩ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ** | | ៩៨.១៨០.៣១៧ | ៣៩៦.៣៥៣.៩៤១ | ៩៧.១២៤.៣២៣ | ៣៩២.០៩០.៨៩២ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (១.៨៦៥.៤២៥) | - | - |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ២៧ | ៨០.៤៥៩.១៥១ | ៣២៣.២៨៤.៨៦៩ | ៩៨.១៨០.៣១៧ | ៣៩៦.៣៥៣.៩៤១ |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ធនាគារ សហពាណិជ្ជ ក.អ. និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

## ១. អំពីធនាគារ

ធនាគារ សហពាណិជ្ជ ក.អ. (ហៅកាត់ថា "ធនាគារ") ត្រូវបានបង្កើតឡើងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៤ ដោយបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ហើយធនាគារជាតិនៃកម្ពុជា បានផ្តល់ជូនអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ដើម្បីធ្វើប្រតិបត្តិការធនាគារនៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦ អនុលោម តាមប្រកាសលេខ ធ៧-០៦-២០៧ ប្រ.ក. ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ។ នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ធនាគារបានទទួលលេខចុះបញ្ជីថ្មីលេខ ០០០០៧០៨៥ ពីក្រសួងពាណិជ្ជកម្ម ។ ធនាគារ គឺជាបុត្រសម្ព័ន្ធរបស់ E.Sun Commercial Bank Ltd. ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅកោះតៃវ៉ាន់ ។ ក្រុមហ៊ុនមេធំជាងគេ គឺក្រុមហ៊ុន E.Sun Financial Holding Company Ltd. ជាក្រុមហ៊ុន ដែលបានចុះបញ្ជី ពាណិជ្ជកម្មនៅកោះតៃវ៉ាន់ និងជាក្រុមហ៊ុនបានចុះបញ្ជីក្នុងផ្សារភាគហ៊ុននៅកោះតៃវ៉ាន់ ។

សកម្មភាពចម្បងរបស់ធនាគារមានដូចជា៖ ទទួលប្រាក់បញ្ញើរយៈពេលខ្លី មធ្យម និងវែងពីស្ថាប័នផ្សេងៗ និងពីអតិថិជនផ្តល់ឥណទាន និងបុរេប្រទានរយៈពេលខ្លី មធ្យម និងវែងជូនស្ថាប័នផ្សេងៗ និងអតិថិជន សេវាកម្មប្តូររូបិយវត្ថុបរទេស សេវាកម្មហិរញ្ញវត្ថុពាណិជ្ជកម្មអន្តរជាតិ អប្បហារកម្មមូលបត្រពាណិជ្ជកម្ម សេវាកម្មប្រតិបត្តិការរវាងអតិថិជន និងអតិថិជន និងសេវាធនាគារផ្សេងៗទៀត ដែលបានអនុញ្ញាតដោយ ធនាគារជាតិនៃកម្ពុជា តាមរយៈស្នាក់ការកណ្តាលរបស់ធនាគារនៅរាជធានីភ្នំពេញ និងការិយាល័យសាខានៅតាមបណ្តាខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុន យូអអ៊ី លែន ហូលឌីង ខូ អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុនបុត្រសម្ព័ន្ធ") ត្រូវបានចុះបញ្ជី ពាណិជ្ជកម្ម នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣ ដែលកាន់កាប់ដោយធនាគារ និងឯកត្តជនជាជនជាតិខ្មែរ ។ សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធគឺកាន់កាប់ដីសម្រាប់ធនាគារប្រើប្រាស់ ។

ទីស្នាក់ការរបស់ធនាគារគឺស្ថិតនៅអគារលេខ ៦១ ផ្លូវលេខ ១៣០ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ធនាគារមានបុគ្គលិកចំនួន ៤២៥ នាក់ នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ (២០១៧: ៤២០ នាក់) ។

## ២. មូលដ្ឋានទូទៅនៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និង គោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ដែលពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ ។

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានអនុម័ត និងផ្តល់សិទ្ធិផ្សាយដោយក្រុមប្រឹក្សាភិបាល នៅ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១៩ ។

## ២. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (ខ) មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម

របាយការណ៍ហិរញ្ញវត្ថុរួម រួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធដែលបានរៀបចំសម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ។ បុត្រសម្ព័ន្ធគឺជាក្រុមហ៊ុនទាំងឡាយណាដែលសម្ព័ន្ធធនាគារ មានអំណាចក្នុងការគ្រប់គ្រងលើផ្នែកហិរញ្ញវត្ថុ និងផ្នែកប្រតិបត្តិការរបស់ក្រុមហ៊ុននោះ ដើម្បីទទួលបានអត្ថប្រយោជន៍ពីសកម្មភាពរបស់ក្រុមហ៊ុននោះ ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានរួមបញ្ចូល ដោយប្រើវិធីសាស្រ្តគណនេយ្យក្នុងការទិញ។ យោងតាមវិធីសាស្រ្តគណនេយ្យ ក្នុងការទិញលទ្ធផលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលបានទិញឬបានលក់ក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានរួមបញ្ចូលចាប់ពីកាលបរិច្ឆេទទិញ ឬរហូតដល់កាលបរិច្ឆេទលក់ ។ នាកាលបរិច្ឆេទទិញ តម្លៃសមស្របនៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានកំណត់រួចជាស្រេច ហើយតម្លៃទាំងនេះត្រូវបានឆ្លុះបញ្ចាំង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ។

ប្រតិបត្តិការអន្តរក្រុមហ៊ុន សមតុល្យនិងចំណេញឬខាតមិនទាន់ទទួលស្គាល់ ដែលកើតមកពីប្រតិបត្តិការអន្តរក្រុមហ៊ុន ត្រូវបានលុបចោល ហើយរបាយការណ៍ហិរញ្ញវត្ថុរួមឆ្លុះបញ្ចាំងតែប្រតិបត្តិការជាមួយភាគីខាងក្រៅតែប៉ុណ្ណោះ ។ ការខាតបង់ដែលបណ្តាលមកពីប្រតិបត្តិការក្នុងសម្ព័ន្ធធនាគារ ដែលចង្អុលបង្ហាញនូវការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ នឹងត្រូវកត់ត្រានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ។ របាយការណ៍ហិរញ្ញវត្ថុរួម ត្រូវបានរៀបចំឡើងដោយប្រើប្រាស់គោលនយោបាយគណនេយ្យរួម ចំពោះប្រតិបត្តិការដូចគ្នា និងព្រឹត្តិការណ៍ផ្សេងៗនៅក្នុងកាលៈទេសៈប្រហាក់ប្រហែលគ្នា ។ ចំណេញ ឬខាតពីការលក់ក្រុមហ៊ុនបុត្រសម្ព័ន្ធគឺជាភាពលម្អៀងរវាងសាច់ប្រាក់បានពីការលក់សុទ្ធ និងភាគហ៊ុនរបស់សម្ព័ន្ធធនាគារលើទ្រព្យសកម្មសុទ្ធរបស់ខ្លួននាកាលបរិច្ឆេទលក់នោះ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលរួម ។

អប្បភាគភាគហ៊ុនគឺជាចំណែកនៃចំណេញឬខាត និងទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលធនាគារកាន់កាប់ដោយផ្ទាល់ឬដោយប្រយោល ។ អប្បភាគភាគហ៊ុនត្រូវបានបង្ហាញដាច់ដោយឡែកក្នុងរបាយការណ៍លទ្ធផលដាច់ដោយឡែក និងក្នុងខ្ទង់មូលធនក្នុងតារាងតុល្យការរួម ដាច់ដោយឡែកពីមូលធនរបស់ម្ចាស់ធនាគារ ។ នៅពេលដែលអប្បភាគភាគហ៊ុនត្រូវបានប៉ាន់ស្មានជាបំណុល នោះវាត្រូវបានបង្ហាញក្រោមខ្ទង់បំណុលក្នុងតារាងតុល្យការរួម ។ ការខាតបង់ចំពោះអប្បភាគភាគហ៊ុន ត្រូវបានបែងចែកដោយធៀបនឹងអត្ថប្រយោជន៍របស់អប្បភាគភាគហ៊ុន បើទោះជាអប្បភាគភាគហ៊ុនមានសមតុល្យ ខ្វះក៏ដោយ ។

យូអេអ៊ី លែន ហូលឌីង ខូ អិលធីឌី ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ មានភាគហ៊ុនដែលមានចំណាត់ថ្នាក់ផ្សេងៗគ្នា ។ ឯកត្តជនកាន់កាប់ភាគហ៊ុនថ្នាក់ "ក" ចំនួន ៥១% ហើយធនាគារកាន់កាប់ហ៊ុនថ្នាក់ "ខ" ចំនួន ៤៩% ។ ការតែងតាំងក្រុមប្រឹក្សាភិបាលគឺជាសិទ្ធិរបស់ភាគទុនិកថ្នាក់ "ខ" ប៉ុណ្ណោះ ។ ធនាគារបានចាត់ទុកថាខ្លួនមានអំណាចលើបុត្រសម្ព័ន្ធ ហេតុនេះរបាយការណ៍ហិរញ្ញវត្ថុរបស់វា ត្រូវបានបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ។

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### (គ) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើម ។

### (ឃ) រូបិយប័ណ្ណសម្រាប់ការវាស់វែង និងការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល ។ ដោយសារធនាគារធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រងក៏បានកំណត់ថាប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងាររបស់ធនាគារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ធនាគារ ។

ប្រតិបត្តិការដែលជារូបិយប័ណ្ណក្រៅពីដុល្លារអាមេរិក ត្រូវបានបង្ហាញជារូបិយប័ណ្ណដុល្លារជាមួយនឹងអត្រាប្តូរប្រាក់នៅថ្ងៃដែលប្រតិបត្តិការបានកើតឡើង ។ សមតុល្យទ្រព្យសកម្ម និងបំណុលដែលជារូបិយប័ណ្ណផ្សេងទៀតនៅថ្ងៃតារាងតុល្យការ ត្រូវបានបង្ហាញជារូបិយប័ណ្ណដុល្លារជាមួយនឹងអត្រាប្តូរប្រាក់នៅក្នុងថ្ងៃដដែលនោះ ។ ភាពខុសគ្នានៃអត្រាប្តូរប្រាក់ដែលកើតឡើង នឹងត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ធនាគារ ។ តួលេខទាំងអស់ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិក ដែលជិតបំផុត ឬលុះត្រាមានការបង្ហាញផ្សេងពីនោះ ។

### (ង) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឲ្យអ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែងអាចខុសគ្នាពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និងការសន្មត់ត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែទៅលើការប៉ាន់ស្មានគណនេយ្យ ត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងកាលបរិច្ឆេទដែលការប៉ាន់ស្មាននោះត្រូវបានកែប្រែឡើងវិញ និងការិយបរិច្ឆេទអនាគតដែលប៉ះពាល់ដោយការកែប្រែនេះ ។

ការប៉ាន់ស្មាន
និងការសន្មត់ដែលមានហានិភ័យកម្រិតខ្ពស់ក្នុងការធ្វើអោយមាននិយត្តកម្មជាសារវន្តទៅលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល នៅក្នុងរយៈពេលបន្ទាប់ដែលបានបញ្ជាក់ខាងក្រោម ។

## ២. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (ង) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

**ភតិសន្យា**

ធនាគារបានចុះកិច្ចសន្យា លើការជួលដី និងអគារមួយចំនួន ដោយការជួលអគារបានបំពេញលក្ខខណ្ឌនៃភតិសន្យាហិរញ្ញប្បទាន។ ក្នុងការបែងចែកកម្រៃភតិសន្យាលើការជួលដី និងអគារ អ្នកគ្រប់គ្រងប្រើការវិនិច្ឆ័យក្នុងការបែងចែកចំណាយហិរញ្ញប្បទាន លើការជួលអគារដោយប្រើអត្រាអប្បបរមាចំនួន៧%។ ការវិនិច្ឆ័យនេះមានផលប៉ះពាល់ដល់បំណុលភតិសន្យាហិរញ្ញវត្ថុ និងចំណាយលើការជួល និងចំណាយហិរញ្ញប្បទាន ។

**ចំណាត់ថ្នាក់ឧបករណ៍មូលធន**

បុត្រសម្ព័ន្ធបានបង្កើត ២ ចំណាត់ថ្នាក់នៃភាគហ៊ុនរួមមាន ចំណាត់ថ្នាក់ ក និង ចំណាត់ថ្នាក់ ខ ។ សិទ្ធិនៅក្នុងការចាត់តាំងសមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានប្រគល់អោយសមាជិកដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ ខ នៃភាគហ៊ុន ។ យោងទៅតាមការវាយតម្លៃនៃក្រុមហ៊ុន យោងទៅតាមការដាក់កម្រិតនៃភាគហ៊ុនចំណាត់ថ្នាក់ ក តម្រូវអោយឧបករណ៍ហិរញ្ញវត្ថុនេះ ត្រូវបានចាត់ថ្នាក់ជាបំណុល ។

ការប៉ាន់ស្មានគណនេយ្យ និងការវិនិច្ឆ័យចម្បង ត្រូវបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ រួមមានការប៉ាន់ស្មាននូវចំនួនដែលអាចប្រមូលបានមកវិញពីឥណទាន និងបុរេប្រទាន សមតុល្យជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ និងការសន្យាឥណទានផ្សេងៗ ដែលបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកក្នុងកំណត់សំគាល់ ៣ (ឈ) ។

### ( ) [illegible]

នៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដារទាំងអស់ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ រួមទាំងបំណកស្រាយ និងវិសោធនកម្មពាក់ព័ន្ធផ្សេងៗ។ អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យ ដែលចាប់ផ្តើមនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១២ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ ។

យោងតាមសារាចរណែនាំលេខ ០៥៨ សហវ-កជគ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៦ ដែលចេញដោយក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុម័តឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុពន្យារពេលអនុវត្តស្តង់ដា CIFRS រហូតដល់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៩ ឬការិយបរិច្ឆេទបន្ទាប់ពីនេះ ។

## ២. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### ( ) [illegible]

សម្ព័ន្ធធនាគារ និងធនាគារ មិនទាន់បានអនុវត្តស្តង់ដារថ្មីក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៅឡើយទេ ។ នៅថ្ងៃអនុម័តរបាយការណ៍ហិរញ្ញវត្ថុ សម្ព័ន្ធធនាគារ និងធនាគារ កំពុងវាយតម្លៃទៅលើសក្តានុពលនៃផលប៉ះពាល់ក្នុងការអនុវត្តស្តង់ដារគណនេយ្យថ្មី និងកែប្រែទៅលើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗខាងក្រោមនេះ ត្រូវបានអនុវត្តដោយធនាគារ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ។ គោលនយោបាយទាំងអស់នេះ ត្រូវបានយកមកអនុវត្តប្រកបដោយសង្គតិភាពនៅគ្រប់ការិយបរិច្ឆេទ លើកលែងតែមានការបញ្ជាក់បន្ថែម ។

### (ក) ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ធនាគារ រួមមានសាច់ប្រាក់ និងសាច់ប្រាក់សមមូល ការផ្តល់ឥណទាន និងគណនីត្រូវទទួល ប្រាក់បញ្ញើ គណនីត្រូវទទួលផ្សេងៗ និងត្រូវទូទាត់ផ្សេងៗ ។ គោលនយោបាយគណនេយ្យលើការទទួលស្គាល់ និងការវាយតម្លៃនូវសមាសធាតុទាំងនេះ ត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកពីគ្នា ។

### (ខ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យធនាគារ ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា ប្រាក់បញ្ញើចរន្តនៅគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀត និងការវិនិយោគរយៈពេលខ្លី ដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល ៣ ខែ ឬតិចជាង និងដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បានដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ។

### (គ) សមតុល្យនៅធនាគារជាតិនៃកម្ពុជា ប្រាក់បញ្ញើនៅធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ

សមតុល្យនៅធនាគារជាតិនៃកម្ពុជា ប្រាក់បញ្ញើនៅធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃដើម ដកចេញតម្លៃឱនភាពសម្រាប់ចំនួនណាដែលមិនអាចប្រមូលវិញបាន ។

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា និងនៅធនាគារជាតិនៃកម្ពុជា ត្រូវបានកត់ត្រាតាមតម្លៃដើម ដកសំវិធានធនខាតបង់ ។ លើកលែងតែប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា គោលការណ៍គណនេយ្យ និងសំវិធានធនត្រូវបានអនុវត្តទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១៧-៣៤៤ ប្រ.ក និងសារាចរណែនាំលេខ ធ៧-០១៨-០០១ សរ.ច.ណ ក្នុងកំណត់សំគាល់ ៣ (ឈ) ខាងលើ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឃ) ប្រាក់បញ្ញើតម្កល់តាមច្បាប់

ប្រាក់បញ្ញើតម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនចុះបញ្ជីរបស់ ក្រុមហ៊ុន និងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។ ប្រាក់បញ្ញើតម្កល់តាមច្បាប់ ត្រូវបានកត់ត្រាទៅតាមតម្លៃដើម ។

### (ង) ឧបករណ៍ហិរញ្ញវត្ថុដេរីវេទីវ

ឧបករណ៍ហិរញ្ញវត្ថុដេរីវេទីវ គឺជាកិច្ចសន្យា ដែលតម្លៃរបស់វាត្រូវបានគេកំណត់ពីតម្លៃបង្គប់តម្លៃសន្ទស្សន៍ ឬតម្លៃអថេរមួយ ឬច្រើន ។ វារួមបញ្ចូលនូវកិច្ចសន្យាប្តូរ កិច្ចព្រមព្រៀងអត្រាអនាគត កិច្ចសន្យាអនាគត កិច្ចសន្យាជម្រើស និងការរួមបញ្ចូលនៃឧបករណ៍ហិរញ្ញវត្ថុទាំងនេះ ។

ឧបករណ៍ហិរញ្ញវត្ថុដេរីវេទីវ ត្រូវបានគេទទួលស្គាល់ជាលើកដំបូង ដោយប្រើនូវតម្លៃសមរម្យ ហើយការចំណេញ ឬខាតដែលកើតឡើងពីការវាស់វែងលើកក្រោយតាមតម្លៃសមរម្យ ត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

### (ច) ការវិនិយោគសម្រាប់លក់

ចំណាត់ថ្នាក់ប្រភេទនេះរួមមាន ការវិនិយោគមូលបត្រដែលធនាគារគ្រោងនឹងកាន់កាប់ ក្នុងរយៈពេលមិនកំណត់ណាមួយ ហើយអាចនឹងលក់ចេញវិញក្នុងករណីដែលធនាគារមានតម្រូវការសាច់ប្រាក់ ឬមានការប្រែប្រួលអត្រាការប្រាក់ អត្រាប្តូរប្រាក់ ឬតម្លៃមូលធន ។

ការវិនិយោគសម្រាប់លក់ត្រូវបានវាស់វែងជាបឋមតាមថ្លៃដើម បន្ទាប់មកទៀតវាត្រូវបានវាស់វែងតាមតម្លៃសមស្រប ។ ចំណេញឬខាតដែលមិនទាន់ទទួលបាន ត្រូវបានកត់ត្រាដោយផ្ទាល់ក្នុងមូលធន ក្រោមខ្ទង់ទុនបម្រុងការវិនិយោគសម្រាប់លក់ ។ នៅពេលដែលមូលបត្រត្រូវបានលក់ចេញ ចំណេញឬខាតបង្គរ ដែលបានកត់ត្រាគ្រាមុនក្នុងមូលធន ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល ជាចំណូលឬចំណាយប្រតិបត្តិការផ្សេងៗ ។ ភាគលាភដែលរកបានក្នុងអំឡុងពេលកាន់កាប់ការវិនិយោគសម្រាប់លក់ ត្រូវបានកត់ ត្រាក្នុងរបាយការណ៍លទ្ធផល ជាចំណូលប្រតិបត្តិការផ្សេងៗ នៅពេលដែលទទួលបានការបង់ប្រាក់ ។ ការខាតដែលបណ្តាលមកពីការថយចុះតម្លៃនៃការវិនិយោគទាំងនោះ ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល និងលុបចេញពីទុនបម្រុងការវិនិយោគសម្រាប់លក់ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ច) ការវិនិយោគសម្រាប់លក់ (ត)

តម្លៃសមស្របនៃការវិនិយោគសម្រាប់លក់ ដែលបានជួញដូរនៅលើទីផ្សារសកម្ម នាកាលបរិច្ឆេទតារាងតុល្យការ គឺអាស្រ័យទៅតាមតម្លៃលក់លើទីផ្សារ ឬទៅតាមតម្លៃដែលឈ្មួញដាក់លក់ (តម្លៃដេញថ្លៃសម្រាប់ទិញនិងលក់) ដោយមិនបានកាត់កងនឹងចំណាយប្រតិបត្តិការទេ ។

### (ឆ) ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃអាចប៉ាន់ស្មានពិត ។ ការប៉ាន់ស្មានត្រូវបានធ្វើឡើងចំពោះគណនីត្រូវទទួល ដែលជាប់សង្ស័យដោយផ្អែកលើការត្រួតពិនិត្យនូវចំនួន ដែលត្រូវទទួលនាកាលបរិច្ឆេទរាយការណ៍ ។

### (ជ) ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទានផ្តល់ឲ្យអតិថិជន ត្រូវបានកត់ត្រានៅក្នុងតារាងតុល្យការតាមប្រាក់ដើម ដកចេញចំនួនទាំងឡាយណាដែលបានលុបចោល ឬសំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ ។

ឥណទានត្រូវបានលុបចោល នៅពេលដែលគ្មានសង្ឃឹមក្នុងការទទួលនូវការទូទាត់សង ។ ការប្រមូលបានមកវិញនូវឥណទានដែលបានលុបចោល ឬតំហាយសំវិធានធនកត់ត្រាពីមុន ត្រូវបានទទួលស្គាល់ជាបម្រែបម្រួលសុទ្ធនៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យនៅក្នុងរបាយការណ៍លទ្ធផល ។

### (ឈ) សំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ

ដើម្បីអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា រាល់ឥណទាន និងបុរេប្រទាន ត្រូវបានចាត់ចំណាត់ថ្នាក់ ដោយយោងទៅតាមសមត្ថភាពនៃការទូទាត់សងរបស់ដៃគូពាណិជ្ជកម្ម ។ សមត្ថភាពនៃការទូទាត់សងនេះ ត្រូវបានវាយតម្លៃដោយផ្អែកទៅតាមបទពិសោធន៍នៃការទូទាត់សងពីមុន លក្ខខណ្ឌហិរញ្ញវត្ថុរបស់កូនបំណុលអាជីវកម្ម និងលំហូរទឹកប្រាក់នាពេលអនាគត និងការស្ម័គ្រចិត្តសងរបស់កូនបំណុលបរិយាកាសហិរញ្ញវត្ថុ និងគុណភាពនៃឯកសារឥណទានដែលប្រមូលបាន ។

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨**

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឈ) សំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ (ត)

មុនថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ ការធ្វើសំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យត្រូវបានគណនាដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃហួសកាលកំណត់សង | សំវិធានធនអប្បបរមា |
|---|---|---|
| ឥណទានធម្មតា/ស្តង់ដារ | <៣០ ថ្ងៃ | ១% |
| ឥណទានឃ្លាំមើល | ≥ ៣០ ថ្ងៃ – ៨៩ ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ≥ ៩០ ថ្ងៃ – ១៧៩ ថ្ងៃ | ២០% |
| ឥណទានសង្ស័យ | ≥ ១៨០ ថ្ងៃ – ៣៥៩ ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | លើសពី ៣៦០ ថ្ងៃ | ១០០% |

ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ ការធ្វើសំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យត្រូវបានកែប្រែដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| **កម្ចីរយៈពេលខ្លី (តិចជាង ឬស្មើមួយឆ្នាំ):** | | |
| បំណុលធម្មតា/ស្តង់ដារ | ≤១៤ ថ្ងៃ | ១% |
| បំណុលឃ្លាំមើល | ១៥ ថ្ងៃ – ៣០ ថ្ងៃ | ៣% |
| បំណុលក្រោមស្តង់ដារ | ៣១ ថ្ងៃ – ៦០ ថ្ងៃ | ២០% |
| បំណុលសង្ស័យ | ៦១ ថ្ងៃ – ៩០ ថ្ងៃ | ៥០% |
| បំណុលបាត់បង់ | ≥ ៩១ ថ្ងៃ | ១០០% |
| **កម្ចីរយៈពេលវែង (ច្រើនជាងមួយឆ្នាំ):** | | |
| បំណុលធម្មតា/ស្តង់ដារ | <៣០ ថ្ងៃ | ១% |
| បំណុលឃ្លាំមើល | ≥៣០ ថ្ងៃ – ៨៩ ថ្ងៃ | ៣% |
| បំណុលក្រោមស្តង់ដារ | ≥៩០ ថ្ងៃ – ១៧៩ ថ្ងៃ | ២០% |
| បំណុលសង្ស័យ | ≥១៨០ ថ្ងៃ – ៣៥៩ ថ្ងៃ | ៥០% |
| បំណុលបាត់បង់ | លើសពី ៣៥៩ ថ្ងៃ | ១០០% |

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨**

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឈ) សំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ (ត)

សម្ព័ន្ធធនាគារ និងធនាគារ បានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធនដែលតម្រូវដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៧ និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៨ ស្តីពី "ចំណាត់ថ្នាក់ហានិភ័យឥណទាន និង សំវិធានធនលើអ៊ីមភែរមិន" សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ។ ឥណទាននិង បុរេប្រទាន ផលិតផល ហិរញ្ញវត្ថុផ្សេងៗ និងកិច្ចសន្យាហិរញ្ញវត្ថុក្រៅតារាងតុល្យការត្រូវបានបែងចែកជាប្រាំថ្នាក់ ហើយត្រូវកត់ត្រាសំវិធានធនអាស្រ័យទៅតាមចំណាត់ថ្នាក់របស់វា ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបានដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) លុះត្រាតែមាន ព័ត៌មានផ្សេងទៀតដែលចង្អុលបង្ហាញពីស្ថានភាពអាក្រក់ជាងនេះ ។

ការផ្លាស់ប្តូរក្នុងចំណាត់ថ្នាក់ហានិភ័យឥណទាន និង សំវិធានធនលើអ៊ីមភែរមិនត្រូវបានអនុវត្តដោយកំណត់ឡើងវិញហើយការផ្លាស់ប្តូរនេះបានធ្វើអោយមានការកើនឡើង នៃការធ្វើវិធានធនលើឥណទាន និងបុរេប្រទាន អាក្រក់ និងជាប់សង្ស័យ សម្រាប់ការិយបរិច្ឆេទពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ចំនួន ៣២៣.៧១៤ ដុល្លារអាមេរិក ។

ភាគរយទាបបំផុតនៃការធ្វើវិធានធនលើឥណទាន និងបុរេប្រទានជាប់សង្ស័យ ត្រូវបានកត់ទុកដោយយោងទៅតាមការចាត់ថ្នាក់ដែលបានកំណត់ទុក ។ នៅពេលដែលមានប្រភពព័ត៌មាន ដែលអាចជឿជាក់បានបង្ហាញថា មានការបាត់បង់អាចនឹងកើតឡើង ច្រើនជាងភាគរយទាបបំផុតដែលបានរំពឹងទុកថា ការធ្វើវិធានធនទំហំធំនឹងត្រូវបានកើតឡើង ។

នៅក្នុងការកំណត់ការធ្វើវិធានធនខាងលើនេះ តម្លៃនៃទ្រព្យសកម្មក្រៅពីប្រាក់តម្កល់ដែលបានដាក់បញ្ចាំមិនត្រូវបានរាប់បញ្ចូល លុះត្រាតែចំណាត់ថ្នាក់នៃកម្ចីគឺជា "បំណុលបាត់បង់" នៅពេលនោះទ្រព្យសកម្មដាក់បញ្ចាំទាំងអស់នឹងត្រូវបានប្រើប្រាស់នៅក្នុងតម្លៃទីផ្សារដែលអនុម័តដោយធនាគារជាតិ ។

ការប្រមូលមកវិញនូវឥណទាន និងបុរេប្រទានដែលបានលុបបំបាត់ចោល និងការបញ្ចូលមកវិញនូវសំវិធានធនពីមុនត្រូវបានបង្ហាញដាច់ដោយឡែក រួមជាមួយនឹងការប្រែប្រួលសុទ្ធនៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យក្នុងរបាយការណ៍លទ្ធផល ។

### (ញ) កិច្ចសន្យាពាក់ព័ន្ធនឹងឥណទានផ្សេងៗ

នៅក្នុងដំណើរការអាជីវកម្មធម្មតា សម្ព័ន្ធធនាគារ និងធនាគារ ចុះកិច្ចសន្យាដែលពាក់ព័ន្ធនឹងឥណទានផ្សេងៗ រួមមាន កិច្ចសន្យាឥណទាន លិខិតឥណទាន និង លិខិតធានាធនាគារផ្សេងៗ ។ គោលនយោបាយគណនេយ្យ និងសំវិធានធន បានអនុវត្តទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០១៧-៣៤៤ ប្រ.ក និង សារាចរណែនាំលេខ ធ៧-០១៨-០០១ ស.រ.ច.ណ ក្នុងកំណត់សំគាល់ ៣(ឈ) ខាងលើ ។

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨**

សំវិធានធនកិច្ចសន្យាក្រៅតារាងតុល្យការ ត្រូវបានបង្ហាញក្នុងខ្ទង់ដាច់ដោយឡែកមួយក្នុងតារាងតុល្យការ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ដ) ការប្រាក់ព្យួរទុក

ការប្រាក់ព្យួរទុក បង្ហាញនូវការប្រាក់លើឥណទានមិនដំណើរការ ដែលបានកត់ត្រាជាសំវិធានធន វាមិនត្រូវបានកត់ត្រាជាចំណូលនោះទេលុះត្រាតែវាទទួលបានជាសាច់ប្រាក់សុទ្ធ ។

ការប្រាក់ព្យួរទុក ត្រូវបានបង្ហាញដោយការដកចេញឥណទាន និងបុរេប្រទាន ។

### (ឋ) ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ

ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានលុបចោលក្នុងការធ្វើរបាយការណ៍ហិរញ្ញវត្ថុរួម ត្រូវបានរាយការណ៍តាមថ្លៃដើម ។ នៅពេលលក់ការវិនិយោគនោះចេញវិញ តម្លៃលម្អៀងរវាងសាច់ប្រាក់បានពីការលក់សុទ្ធ និងតម្លៃយោងរបស់វា ត្រូវបានកត់ត្រាជាចំណេញ ឬខាតក្នុងការលក់ នៅក្នុងរបាយការណ៍លទ្ធផលរបស់ធនាគារ ។

### (ឌ) ភតិសន្យា

ភតិសន្យា ត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញប្បទាន នៅពេលដែលមានការផ្ទេរហានិភ័យ និងអត្ថប្រយោជន៍នៃកម្មសិទ្ធនៃទ្រព្យសកម្មឲ្យអ្នកជួល ។ ភតិសន្យាហិរញ្ញប្បទានជាទ្រព្យសកម្មត្រូវបានទទួលស្គាល់ដំបូងដោយវាស់វែងជាតម្លៃស្មើនឹងទ្រព្យសកម្មដែលជួល ឬប្រសិនបើតម្លៃទាបជាងតម្លៃទីផ្សារ ត្រូវគិតតាមតម្លៃបច្ចុប្បន្ននៃថ្លៃឈ្នួលអប្បបរមានៃភតិសន្យា ។ បន្ទាប់ពីការទទួលស្គាល់ដំបូង ទ្រព្យសកម្មត្រូវទទួលស្គាល់ផ្អែកតាមគោលនយោបាយគណនេយ្យពាក់ព័ន្ធ និងទ្រព្យសកម្មនោះ ។

ភតិសន្យាផ្សេងទៀត ត្រូវបានចាត់ទុកជាភតិសន្យាប្រតិបត្តិការ ។ ភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ជាចំណាយតាមវិធីសាស្ត្ររំលស់ថេរទៅតាមថេរវេលានៃភតិសន្យា ។

### (ឍ) ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបិយ ដែលរួមមានកុំព្យូទ័រសូហ្វវែរ ត្រូវបានកំណត់ដោយតម្លៃដើមដករំលស់បង្គរ និងឱនភាពនៃតម្លៃបង្គរប្រសិនបើមាន ។

ការទិញកុំព្យូទ័រសូហ្វវែរត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានទិញ និងនាំយកសូហ្វវែរនោះមកប្រើប្រាស់ ។ រំលស់ត្រូវបានគណនាផ្អែកលើ មូលដ្ឋានរំលស់ថេរក្នុងរយៈពេល ៥ ឆ្នាំ ។ ចំណាយដែលកើតឡើងក្នុងការធ្វើគម្រោង ឬការវាយតម្លៃនូវកុំព្យូទ័រសូហ្វវែរ ឬការថែទាំក្រោយពេលដាក់ឲ្យប្រើប្រាស់មិនត្រូវបានចាត់ចូលជាថ្លៃដើមនោះទេ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ណ) ទ្រព្យ និងបរិក្ខារ

(i) ផ្នែកនៃទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពតម្លៃបង្គរប្រសិនបើមាន ។ នៅពេលដែលធាតុនៃទ្រព្យ និងបរិក្ខារមានអាយុកាលកំណត់ប្រើប្រាស់ខុសៗគ្នា ទ្រព្យទាំងនោះ ត្រូវបានចាត់ទុកជាធាតុផ្សេងគ្នានៃទ្រព្យ និងបរិក្ខារ ។

(ii) រំលស់លើទ្រព្យ និងបរិក្ខារត្រូវបានទទួលស្គាល់ជាចំណាយក្នុងរបាយការណ៍លទ្ធផល ដោយផ្អែកលើមូលដ្ឋានរំលស់ថេរតាមការប៉ាន់ស្មាននៃអាយុកាលប្រើប្រាស់របស់ទ្រព្យ និងបរិក្ខារនីមួយៗដូចខាងក្រោម៖

| | |
|---|---|
| អគារ | ២០ ឆ្នាំ |
| ការកែលម្អអគារ | ១០ ឆ្នាំ |
| បរិក្ខារការិយាល័យ | ៤ ឆ្នាំ |
| យានយន្ត | ៤ ឆ្នាំ |
| បរិក្ខារផ្នែកព័ត៌មានវិទ្យា និងកុំព្យូទ័រ | ៤ ឆ្នាំ |

វិធីសាស្ត្ររំលស់ អាយុកាល និងតម្លៃកាកសំណល់ ត្រូវបានវាយតម្លៃនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ និងធ្វើនិយ័តកម្មតាមការសមស្រប ។

(iii) ទ្រព្យកំពុងបង្កើត មិនត្រូវបានរំលស់ទេ រហូតទាល់តែទ្រព្យនោះ ត្រូវបានបញ្ចប់ និងបានដាក់ឲ្យប្រើប្រាស់ ។

(iv) ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារដែលបានទទួលស្គាល់រួច មកហើយ ត្រូវបានរួមបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម នៅពេលដែលអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលនឹងអាចមានឡើង និងបញ្ចូលទៅក្នុងធនាគារនៅក្នុងលក្ខខណ្ឌលើសពីស្តង់ដារដើមនៃទ្រព្យសកម្មដែលកំពុងមាន ។ រាល់ការចំណាយបន្ទាប់ផ្សេងទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

(v) ចំណេញ ឬខាតពីការបោះចោល ឬការលក់ចេញនៃទ្រព្យ និងបរិក្ខារណាមួយ ត្រូវបានកំណត់ដោយភាពខុសគ្នារវាងប្រាក់ចំណូលសុទ្ធពីការលក់ និងតម្លៃយោងនៃទ្រព្យ និងបរិក្ខារនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលនៅថ្ងៃបោះចោល ឬលក់ចេញ ។

(vi) ទ្រព្យ និងបរិក្ខារ ដែលបានដករំលស់អស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ថ្ងៃដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ ឬលុបចោល ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ត) ឱនភាពនៃទ្រព្យសកម្ម

*(i) ទ្រព្យសកម្មហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃនាការិយបរិច្ឆេទនៃការធ្វើរបាយការណ៍ ដើម្បីកំណត់ថាតើមានភស្តុតាងណាមួយដែលបង្ហាញថា ទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះមានឱនភាពនៃតម្លៃ ។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវចាត់ទុក ថាមានឱនភាពនៃតម្លៃ ប្រសិនបើមានហេតុការណ៍ណាមួយ ឬច្រើនជះឥទ្ធិពលជាអវិជ្ជមានទៅលើលំហូរ ទឹកប្រាក់ប៉ាន់ស្មាននាពេលអនាគតដល់ទ្រព្យសកម្មនោះ ។ ករណីនេះ មិនត្រូវបានប្រើប្រាស់សម្រាប់ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជននោះទេ ដោយវាត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយ ឡែកនៅក្នុងកំណត់សំគាល់ ៣ (ឈ) ។

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុសំខាន់ៗ ត្រូវបានត្រួតពិនិត្យលើឱនភាពនៃតម្លៃតាមទ្រព្យសកម្មនីមួយៗ ។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលនៅសល់ត្រូវបានវាយតម្លៃជារួម សម្រាប់ទ្រព្យសកម្មដែលមានហានិភ័យឥណទានស្រដៀងគ្នា ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវដកចេញ ប្រសិនបើមានព្រឹត្តិការណ៍កើតឡើងក្រោយពីការទទួលស្គាល់ការខាតបង់លើឱនភាពនៃតម្លៃតម្រូវឲ្យដកចេញ ។

*(ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ត្រូវបានត្រួតពិនិត្យនៅរាល់ការិយបរិច្ឆេទនៃរបាយកាណ៍ហិរញ្ញវត្ថុ ដើម្បីកំណត់ថាតើមានកត្តា ដែលនាំឲ្យមានឱនភាពឬទេ ។ ក្នុងករណីដែលមានកត្តាទាំងនោះកើតឡើង ការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មត្រូវបានធ្វើឡើង ។

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺផ្អែកលើតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃទីផ្សារដកចំណាយលក់ចេញ ។ ក្នុងការវាយតម្លៃលើតម្លៃប្រើប្រាស់លំហូរទឹកប្រាក់ រំពឹងទុកនាពេលអនាគត ត្រូវបានបញ្ចុះទៅតម្លៃបច្ចុប្បន្ន ដោយប្រើប្រាស់អត្រាការប្រាក់មុនដកពន្ធ ដែលឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ន លើតម្លៃពេលវេលានៃសាច់ប្រាក់ និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ។ ដើម្បីត្រួតពិនិត្យ លើឱនភាពនៃតម្លៃទ្រព្យសកម្ម ត្រូវបញ្ចូលគ្នាទៅជាក្រុមតូចៗទៅតាមទ្រព្យសកម្ម ដែលអាចបង្កើតសាច់ប្រាក់ពីការបន្តប្រើប្រាស់ ដែលមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃសាច់ប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត ("ឯកតាបង្កើតសាច់ប្រាក់") ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកវិញបាន ។ ការខាតបង់ពីឱនភាពនៃតម្លៃ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ថ) ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារនានា

ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃនៃប្រាក់តម្កល់ ។

### (ទ) បំណុលផ្សេងៗ

បំណុលផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃដើម ។

### (ធ) ទុនបម្រុងទូទៅ

ទុនបម្រុងទូទៅ ត្រូវបានបង្កើតឡើងសម្រាប់បង្ការនឹងហានិភ័យហិរញ្ញវត្ថុទូទៅរបស់ធនាគារ ។ ក្រុមប្រឹក្សាភិបាលមានការប្រុងប្រយ័ត្នទៅលើការប្រើប្រាស់ និងការរក្សាទុកទុនបម្រុងទូទៅ ។

### (ន) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងតារាងតុល្យការ នៅពេលដែលធនាគារមាននូវកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកិច្ចសន្យា ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីពេលមុន និងអាចជាលទ្ធភាពដែល តម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវន្ត សំវិធានធន ត្រូវបានកំណត់ដោយការបញ្ចុះតម្លៃចលនាសាច់ប្រាក់ ដែលរំពឹងទុកនាពេលអនាគតតាមអត្រាមុនបង់ពន្ធ ព្រោះវាឆ្លុះបញ្ចាំងពីការប៉ាន់ស្មានទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលានៃប្រាក់កាស និងដោយសមស្របទៅនឹងហានិភ័យជាក់លាក់នៃបំណុល ។

### (ប) ការទទួលស្គាល់ប្រាក់ចំណូល

ចំណូលការប្រាក់លើឥណទាន និងឥណទានលើលសមតុល្យដំណើរការ និងប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានទទួលស្គាល់ ដោយផ្អែកលើមូលដ្ឋានបង្គរជារៀងរាល់ថ្ងៃ ។ ការប្រាក់លើឥណទានមិនដំណើរការ មិនត្រូវបានកត់ត្រាជាចំណូលនោះទេ លុះត្រាតែវាទទួលបានជាសាច់ប្រាក់សុទ្ធ ។

កម្រៃលើការចាត់ចែងផ្តល់ឥណទាន និងកម្រៃជើងសារលើសេវាកម្ម និងឧបករណ៍ហិរញ្ញវត្ថុដែលបានផ្តល់ទៅឲ្យអតិថិជន ត្រូវបានទទួលស្គាល់ជាចំណូលទៅតាមថេរវេលានៃសេវាកម្ម និងឧបករណ៍ហិរញ្ញវត្ថុដែលបានផ្តល់ ។ កម្រៃឥណទានដែលមិនបានធ្វើរំលស់ត្រូវបានបង្ហាញជាការកាត់បន្ថយពីឥណទាន និងបុរេប្រទានផ្តល់ឲ្យអតិថិជន ។

កម្រៃលើកិច្ចសន្យា និងកម្រៃការធានាលើសេវាកម្មផ្សេងៗ និងឧបករណ៍ហិរញ្ញវត្ថុនានា ដែលផ្តល់ឲ្យអតិថិជនត្រូវបានទទួលស្គាល់ជាចំណូលនៅពេលប្រតិបត្តិការកើតឡើង ឬពេលសន្យាផ្តល់ឥណទានបាន ផុតកំណត់ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ប) ការទទួលស្គាល់ប្រាក់ចំណូល (ត)

កម្រៃសេវាកម្ម ដែលតំណាងឲ្យការទទួលបានវិញនូវកម្រៃដែលបានបង់សម្រាប់ការបន្តដល់សេវា (ដូចជាការរក្សារ និងចាត់ចែងឥណទានដែលមាន) ត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្ម ត្រូវបានបំពេញ ។

### (ផ) ចំណាយលើការប្រាក់

ចំណាយលើការប្រាក់ទៅលើប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរជារៀងរាល់ថ្ងៃ ។

### (ព) ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញ រួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល លើកលែងតែក្នុងករណីដែលពន្ធលើប្រាក់ចំណេញទាក់ទងទៅនឹងធាតុណាដែលបានទទួលស្គាល់ជាផ្នែកមួយនៃមូលធន ។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថា ត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

ពន្ធពន្យារ ត្រូវបានកំណត់តាមវិធីសាស្ត្រតារាងតុល្យការលើភាពលំអៀងបណ្តោះអាសន្នរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ ។ ចំនួននៃពន្ធពន្យារដែលបានកំណត់នោះ គឺផ្អែកលើលក្ខណៈដែលអាចប្រើប្រាស់បាន ឬអាចទូទាត់បានដែលនឹងកើតឡើងរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល ដោយប្រើអត្រាពន្ធកំណត់នៅថ្ងៃតារាងតុល្យការ ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់តែក្នុងករណីអាចនឹងកើតមានឡើងនូវប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដែលអនុញ្ញាតឲ្យប្រើប្រាស់កាត់កងជាមួយពន្ធពន្យារនោះបាន ។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានកាត់បន្ថយក្នុងករណីមិនអាចមាននូវការប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន ។

### (ភ) អត្ថប្រយោជន៍របស់និយោជិត

*(i) អត្ថប្រយោជន៍ពេលចូលនិវត្ត*

ធនាគារ ផ្តល់អត្ថប្រយោជន៍ដល់បុគ្គលិកពេលចូលនិវត្តចំនួន ៦% នៃប្រាក់ខែគោលសរុប ចាប់ពីថ្ងៃចូលបម្រើការងារជាមួយធនាគារ ដល់ពេលចូលនិវត្តស្ម័គ្រចិត្ត នៅអាយុ ៥៥ ឆ្នាំ ឬចូលនិវត្តនៅអាយុ ៦០ ឆ្នាំ ឬប្រសិនបើបុគ្គលិកមិនអាចបម្រើការងារបានដោយសារតែសតិ មិនប្រក្រតី ឬពិការភាព ។

មិនមានអត្ថប្រយោជន៍ផ្សេងទៀត ត្រូវបានរក្សាទុកសម្រាប់អត្ថប្រយោជន៍របស់និយោជិតទេ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ភ) អត្ថប្រយោជន៍របស់និយោជិត (ត)

*(ii) អត្ថប្រយោជន៍និយោជិត*

**អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី**

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី ត្រូវបានកត់ត្រាជាបង្គរក្នុងការិយបរិច្ឆេទដែលនិយោជិតបានបំពេញការងារជូនសម្ព័ន្ធធនាគារ និងធនាគារ ។

**អត្ថប្រយោជន៍និយោជិតរយៈពេលវែងផ្សេងៗ**

អត្ថប្រយោជន៍និយោជិតរយៈពេលវែងផ្សេងៗ ដែលជាកាតព្វកិច្ចសុទ្ធរបស់ក្រុមហ៊ុន គឺជាចំនួននៃអត្ថប្រយោជន៍ដែលនិយោជិតទទួលបាន ដោយដោះដូរជាមួយសេវាកម្មដែលពួកគេផ្តល់ជូនក្រុមហ៊ុននៅពេលបច្ចុប្បន្ន និងពេលអតីតកាល ។ អត្ថប្រយោជន៍នេះត្រូវបានបញ្ចុះតម្លៃ ដើម្បីកំណត់នូវតម្លៃនាពេលបច្ចុប្បន្ន ។ ការកំណត់តម្លៃនេះត្រូវបានកត់ទុកនៅក្នុងប្រាក់ចំណេញ ឬខាតនៅក្នុងពេលបច្ចុប្បន្នកាល ។

### (ម) សម្ព័ន្ធញាតិ

ភាគីដែលត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិ ប្រសិនបើភាគីនោះមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោល ឬមានឥទ្ធិពលខ្លាំងទៅលើភាគីមួយទៀតក្នុងការធ្វើសេចក្តីសម្រេចហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬធនាគារ និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលខ្លាំង ។ សម្ព័ន្ធញាតិអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ហើយក៏រួមបញ្ចូលនូវសមាជិកគ្រួសារជិតស្និទ្ធជាមួយនឹងរូបវន្តបុគ្គលជាសម្ព័ន្ធញាតិផងដែរ ។

ក្រុមហ៊ុនសម្ព័ន្ធញាតិសំដៅទៅលើក្រុមហ៊ុនមេ ក្រុមហ៊ុនមេធំបំផុត ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនសមាគតរបស់ពួកគេ ។

តាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សម្ព័ន្ធញាតិរួមបញ្ចូលផងដែរ នូវរូបវន្តបុគ្គលដែលមានភាគហ៊ុនយ៉ាងតិចចំនួន ១០% នៃដើមទុនរបស់ធនាគារ ឬនៃសិទ្ធិបោះឆ្នោត ទោះជាកាន់កាប់ដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ឬរូបវន្តបុគ្គលណាដែលរួមចំណែកក្នុងផ្នែករដ្ឋបាល ការដឹកនាំ ការគ្រប់គ្រង ឬ ការរៀបចំ និងការអនុវត្តនូវការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឃ) អនុបំណុល

អនុបំណុល ត្រូវបានចាត់ទុកថាជាបំណុលហិរញ្ញវត្ថុនៅពេលដែលមានកិច្ចសន្យាកាតព្វកិច្ចក្នុងការទូទាត់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុដល់ក្រុមហ៊ុនផ្សេងទៀត ឬដើម្បីផ្លាស់ប្តូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬ បំណុលហិរញ្ញវត្ថុជាមួយនឹងក្រុមហ៊ុនដទៃទៀត ក្រោមលក្ខខណ្ឌដែលមិនសមប្រកបដល់ក្រុមហ៊ុនបើមិនដូច្នេះទេ វាត្រូវបានចាត់ទុកថាជាមូលធន ។

អនុបំណុលដែលបានអនុម័តដោយ ធនាគារជាតិនៃកម្ពុជា ត្រូវបានចាត់ទៅក្នុងគណនីថ្នាក់ទី II ក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ក្រុមហ៊ុនស្របតាម គោលការណ៍ណែនាំរបស់ធនាគារជាតិកម្ពុជា ។

## ៤. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងសម្រាប់ជាការបង្ហាញប៉ុណ្ណោះ ដោយប្រើអត្រាប្តូរប្រាក់មធ្យមជាផ្លូវការ ប្រកាសដោយធនាគារជាតិនៃកម្ពុជា នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដែល ១ ដុល្លារអាមេរិក ស្មើនឹង ៤.០១៨ រៀល (២០១៧: ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៣៧ រៀល) ។ តួលេខជាប្រាក់រៀលនេះ មិនត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់រៀល ឬនឹងត្រូវប្តូរជាប្រាក់រៀលនាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ ។

## ៥. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| **សម្ព័ន្ធធនាគារ និងធនាគារ** | | | | |
| គណនីចរន្ត | ៣០.២៨២.៩៧៨ | ១២១.៦៧៧.០០៦ | ៥២.៤៧១.៦៨៦ | ២១១.៨២៨.១៩៨ |
| ទុនបម្រុងកាតព្វកិច្ច (ក) | ៥៣.៨៨៤.១៦២ | ២១៦.៥០៦.៥៦៣ | ៥៨.៨៨៣.៩៦៩ | ២៣៧.៧១៤.៥៨២ |
| ប្រាក់តម្កល់ធានាលើដើមទុន (ខ) | ៨.០០០.០០០ | ៣២.១៤៤.០០០ | ៨.០០០.០០០ | ៣២.២៩៦.០០០ |
| វិញ្ញាបនបត្រប្រាក់បញ្ញើដែលអាចជួញដូរបាន (គ) | ៤.៤៩៩.៨០១ | ១៨.០៨០.២០០ | ៣.២៩១.៦៥២ | ១៣.២៨៨.៣៩៨ |
| | ៩៦.៦៦៦.៩៤១ | ៣៨៨.៤០៧.៧៦៩ | ១២២.៦៤៧.៣០៧ | ៤៩៥.១២៧.១៧៨ |

## ៥. សមតុល្យនៅធនាគារជាតិនៃកម្ពុជា (ត)

### (ក) ទុនបម្រុងកាតព្វកិច្ច

ទុនបម្រុងកាតព្វកិច្ច គឺជាទុនបម្រុងអប្បបរមា ដែលត្រូវបានគណនាតាមអត្រា ៨% (២០១៧៖ ៨%) នៃប្រាក់បញ្ញើរបស់អតិថិជនជាប្រាក់រៀល និង ១២.៥% (២០១៧៖ ១២.៥%) នៃប្រាក់បញ្ញើរបស់អតិថិជនជារូបិយប័ណ្ណផ្សេងៗ ។

### (ខ) ប្រាក់តម្កល់ធានាលើដើមទុន

យោងតាមប្រកាសលេខ ធ៧-០១-១៣៦ ប្រ.ក. ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ចេញដោយធនាគារជាតិនៃកម្ពុជា ស្តីពីប្រាក់តម្កល់ធានាលើដើមទុន តម្រូវឲ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ តម្កល់ប្រាក់ចំនួន ១០% នៃដើមទុនចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ។ ប្រាក់តម្កល់នេះនឹងត្រូវបង្វិលជូនធនាគារវិញ នៅពេលធនាគារស្ម័គ្រចិត្ត បញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ហើយប្រាក់តម្កល់នេះមិនសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារទេ ។

### (គ) វិញ្ញាបនបត្រប្រាក់បញ្ញើដែលអាចជួញដូរបាន

ធនាគាបានចេញវិញ្ញាបនបត្រប្រាក់បញ្ញើដែលអាចចចារបាន ("ហៅកាត់ថា NCD") ជាមួយធនាគារជាតិ នៃកម្ពុជា ដែលដាក់ជាទ្រព្យបញ្ចាំសម្រាប់ទូទាត់ និងជម្រះបញ្ជីគណនីភាព ។ កាលកំណត់របស់ NCD គឺមានរយៈពេលបីខែ ។

### (ឃ) អត្រាការប្រាក់

គណនីចរន្ត គឺជាគណនីដែលមិនមានការប្រាក់ ។ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ ប្រាក់តម្កល់ធានាលើដើមទុន និងទុនបម្រុងកាតព្វកិច្ចទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំ ដូចខាងក្រោម៖

| | ២០១៨ | ២០១៧ |
|---|---|---|
| ទុនបម្រុងកាតព្វកិច្ច | 0%-0.៧៣% | 0.៦២%-0.៧៨% |
| ប្រាក់តម្កល់ធានាលើដើមទុន | 0.៨៦%-0.៦២% | 0.៣២%-0.៣៦% |
| វិញ្ញាបនបត្រប្រាក់បញ្ញើដែលអាចជួញដូរបាន | 0.៧៣%-0.៨៩% | 0.៦៩%-0.៨៩% |

## ៦. សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| **សម្ព័ន្ធធនាគារ** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ធនាគារក្នុងស្រុកៈ | | | | |
| គណនីចរន្ត | ១.៨៣៤.៩៩១ | ៧.៣៧០.៩៨៥ | ៥៥០.៧៦៩ | ២.២២៣.៨៥៤ |
| ប្រាក់បញ្ញើមានកាលកំណត់ រយៈពេលវែង | ១.២០០.០០០ | ៤.៨២១.៦០០ | - | - |
| ធនាគារក្រៅស្រុកៈ | | | | |
| គណនីចរន្ត | ១៥.៤៤៥.៩៣៩ | ៦២.០៦១.៧៨៣ | ១៦.៥៩៨.៤៧៤ | ៦៧.០០៨.០៤០ |
| គណនីសន្សំ | ៣.៣៨៩.៨៤៨ | ១៣.៦២០.៥៧០ | ១.១៦៣.៦២០ | ៤.៦៩៧.៥៣៤ |
| | ២១.៨៧០.៣១៨ | ៨៧.៨៧៤.៩៣៨ | ១៨.៣១២.៨៦៣ | ៧៣.៩២៩.០២៨ |
| សំវិធានធនតាមច្បាប់ (កំណត់សំគាល់៧ (ខ)) | (២១០.៨៣៨) | (៨៤៥.៥៤០) | - | - |
| | ២១.៨៧០.៣១៨ | ៨៧.៨៧៤.៩៣៨ | ១៨.៣១២.៨៦៣ | ៧៣.៩២៩.០២៨ |

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| **ធនាគារ** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ធនាគារក្នុងស្រុកៈ | | | | |
| គណនីចរន្ត | ១.០០៨.០២២ | ៤.០៥០.២៣២ | ២៧២.៤៤១ | ១.០៩៩.៨៤៤ |
| ប្រាក់បញ្ញើមានកាលកំណត់ រយៈពេលវែង | ១.២០០.០០០ | ៤.៨២១.៦០០ | - | - |
| ធនាគារក្រៅស្រុកៈ | | | | |
| គណនីចរន្ត | ១៥.៤៤៥.៩៣៩ | ៦២.០៦១.៧៨៣ | ១៦.៥៩៨.៤៧៤ | ៦៧.០០៨.០៤០ |
| គណនីសន្សំ | ៣.៣៨៩.៨៤៨ | ១៣.៦២០.៥៧០ | ១.១៦៣.៦២០ | ៤.៦៩៧.៥៣៤ |
| | ២១.០៤៣.៨០៩ | ៨៤.៥៥៤.១៨៥ | ១៨.០៣៤.៥៣៥ | ៧២.៨០៥.៤១៨ |
| សំវិធានធនតាមច្បាប់ (កំណត់សំគាល់ ៧(ខ)) | (២១០.៨៣៨) | (៨៤៥.៥៤០) | - | - |
| | ២០.៨៣៣.៩៧១ | ៨៣.៧០៨.៦៤៥ | ១៨.០៣៤.៥៣៥ | ៧២.៨០៥.៤១៨ |

គណនីចរន្ត គឺជាគណនីដែលមិនមានការប្រាក់ ។ គណនីសន្សំ ទទួលបានការប្រាក់ចាប់ពី ១% ដល់ ១.២៥% ក្នុងមួយឆ្នាំ នៅពេលដែលថេរវេលានៃប្រាក់តម្កល់មានរយៈពេល ៣ ខែ នោះអត្រាការប្រាក់គឺចាប់ពី ០% ដល់ ២% ក្នុងមួយឆ្នាំ ។

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨**

## ៧. ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - សុទ្ធ

### (ក) វិភាគតាមប្រភេទឥណទាន

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| **សម្ព័ន្ធធនាគារ និងធនាគារ** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ឥណទានពាណិជ្ជកម្ម៖ | | | | |
| ឥណទានមានកាលកំណត់ | ៧០.៣១៣.៨៥៦ | ២៨២.៥២១.០៧៣ | ៦៨.៨៥៥.៣៤៣ | ២៧៧.៩៦៩.០២០ |
| ឥណទានវិបារូបន៍ | ៧.៨៦៧.៤២៥ | ៣១.៦១១.៣១៤ | ១០.៤១០.២៩០ | ៤២.០២៦.៣៤១ |
| សក្ខីបត្រឥណទានជំនឿទុកចិត្ត | ៨០២.០១២ | ៣.២២២.៤៨៤ | ១.១៥៣.១០៦ | ៤.៦៥៥.០៨៩ |
| ឥណទានពាណិជ្ជកម្មផ្សេងៗ | ៥.១២២.៧៧៤ | ២០.៥៨៣.៣០៦ | ១៤.៨៣៨.៨៦០ | ៥៩.៩០៤.៤៧៨ |
| ឥណទានអតិថិជនប្រើប្រាស់៖ | | | | |
| ឥណទានមានកាលកំណត់ | ៩៨.៤៣០.០២៦ | ៣៩៥.៤៩១.៨៤៤ | ៥១.៨៩៧.៨០៦ | ២០៩.៥១១.៤៤៣ |
| ឥណទានវិបារូបន៍ | ២៥.៥៩២.៧៥៨ | ១០២.៦៣០.៨០២ | ៣៤.៥៧៤.៤៣៩ | ១៣៩.៥៧៧.០១០ |
| ប័ណ្ណឥណទាន | ៣.៩៦៦.៩៥៩ | ១៥.៩៣៩.២៤១ | ៣.៣៨៥.៥៩១ | ១៣.៦៦៧.៦៣១ |
| ឥណទានអ្នកប្រើប្រាស់ផ្សេងៗ | ១១៧.៣៣០.១៦៧ | ៤៧១.៤៣២.៦១១ | ១៤៦.៨១១.៦៦៧ | ៥៩២.៦៧៨.៦៩៩ |
| | ៣២៩.៣៧៥.៩៧៧ | ១.៣២៣.៤៣២.៦៧៥ | ៣៣១.៩២៧.១០២ | ១.៣៣៩.៩៨៩.៧១១ |
| សំវិធានធនលើឥណទានអាក្រក់ និងសង្ស័យ៖ | | | | |
| សំវិធានធនជាក់លាក់ | (១០.៤៧៩.៥២៥) | (៤២.១០៦.៧៣០) | (១១.៨៣១.៦៣០) | (៤៧.៧៦៤.២៩០) |
| សំវិធានធនទូទៅ | (៣.៤៧២.២៥៤) | (១៣.៩៥១.៥១៧) | (៣.៦៨៦.៨៣៥) | (១៤.៨៨៣.៧៥៣) |
| | (១៣.៩៥១.៧៧៩) | (៥៦.០៥៨.២៤៧) | (១៥.៥១៨.៤៦៥) | (៦២.៦៤៨.០៤៣) |
| | ៣១៥.៤២៤.១៩៨ | ១.២៦៧.៣៧៤.៤២៨ | ៣១៦.៤០៨.៦៣៧ | ១.២៧៧.៣៤១.៦៦៨ |

**កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨**

## ៧. ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - សុទ្ធ (ត)

### (ខ) សំវិធានធនលើអ៊ឹមភែរមិន

(i) សំវិធានធនលើអ៊ឹមភែរមិនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| សំវិធានធនលើឥណទាន និងបុរេប្រទានខាតបង់ | (១៤.៣៣៣.២៩៤) | (៥៧.៥៩១.១៧៥) | (៣២.៧៣៤.៤៤៨) | (១៣២.១៤៨.៩៦៧) |
| សំវិធានធនលើឥណទានប្រាក់បញ្ញើប្រាក់តម្កល់នៅធនាគារនានា | (២១០.៤៣៨) | (៨៤៥.៥៤០) | - | - |
| សំវិធានធនលើសមាសធាតុក្រៅតារាងតុល្យការ | (៣២២.០៨៩) | (១.២៩៤.១៥៤) | - | - |
| | (១៤.៨៦៥.៨២១) | (៥៩.៧៣០.៨៦៩) | (៣២.៧៣៤.៤៤៨) | (១៣២.១៤៨.៩៦៧) |

(ii) បម្រែបម្រួលនៃសំវិធានធនសម្រាប់ឥណទានសង្ស័យ និងបុរេប្រទាន មានដូចខាងក្រោម៖

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| សមតុល្យនាថ្ងៃទី ១ខែមករា | ១៥.៥១៨.៤៦៥ | ៦២.៦៤៨.០៤៣ | ៣៨.៨៨៣.៧៨១ | ១៥៦.៩៧៣.៨២៤ |
| សំវិធានធនសម្រាប់ការិយបរិច្ឆេទ | ១៤.៣៣៣.២៩៤ | ៥៧.៥៩១.១៧៥ | ៣២.៧៣៤.៤៤៨ | ១៣២.១៤៨.៩៦៧ |
| ការលុបចោល | (១៥.៨៩៩.៩៨០) | (៦៣.៨៨៦.១២០) | (៥៦.០៩៩.៧៦៤) | (២២៦.៤៧៤.៧៤៨) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (២៩៤.៨៥១) | - | - |
| សមតុល្យនាថ្ងៃទី ៣១ខែធ្នូ | ១៣.៩៥១.៧៧៩ | ៥៦.០៥៨.២៤៧ | ១៥.៥១៨.៤៦៥ | ៦២.៦៤៨.០៤៣ |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

## ៧. ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - សុទ្ធ (ត)

### (គ) តាមការធានាលើឥណទានដំណើរការ និងឥណទានមិនដំណើរការ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ឥណទានធម្មតា | | | | |
| មានការធានា | ២៤៧.៨៤៣.៩៤៨ | ៩៩៤.២២៩.៧៨៣ | ២៧៦.៧៣៧.៨២០ | ១.១១៧.១៩០.៥៧៩ |
| មិនមានការធានា | ៣៥.៧៩១.១៩៤ | ១៤៣.៨០៩.០១៧ | ២៦.៥០៧.៤២៥ | ១០៧.០១០.៤៧៥ |
| ឥណទានឃ្លាំមើល | | | | |
| មានការធានា | ៣៥.៥៥០.៨០១ | ១៤២.៨៤៣.១១៨ | ៤.២៥៩.៣៨០ | ១៧.១៩៥.១១៧ |
| មិនមានការធានា | ៥១.៩៩៣ | ២០៨.៩០៨ | ៧០.៨០១ | ២៨៥.៨២៤ |
| ឥណទានក្រោមស្តង់ដារ | | | | |
| មានការធានា | ១.៧៨២.៩២១ | ៧.១៦៣.៧៧៧ | ៣.២៤៩.៥៣២ | ១៣.១១៨.៣៦១ |
| មិនមានការធានា | ៣០.៥៧៥ | ១២២.៨៥០ | ១០.៤៧០.៥៨៣ | ៤២.២៦៩.៧៤៤ |
| ឥណទានសង្ស័យ | | | | |
| មានការធានា | ៤.២២៣.៤០២ | ១៦.៩៦៩.៦២៩ | ៥.៣៩០.៩៥០ | ២១.៧៦៣.២៦៥ |
| មិនមានការធានា | ៣២.៦៥៦ | ១៣១.២១២ | ៤៣.៧៨១ | ១៧៦.៧៤៤ |
| ឥណទានបាត់បង់ | | | | |
| មានការធានា | ៤.៤២៣.២១២ | ១៧.៧៧២.៨៦៦ | ៥.១៨៥.៩៣៦ | ២០.៩៣៥.៦២៤ |
| មិនមានការធានា | ៤៥.២៧៥ | ១៨១.៩១៥ | ១០.៨៩៤ | ៤៣.៩៧៩ |
| | ៣២៩.៣៧៥.៩៧៧ | ១.៣២៣.៤៣២.៦៧៥ | ៣៣១.៩២៧.១០២ | ១.៣៣៩.៩៨៩.៧១១ |

### (ឃ) តាមហានិភ័យ

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ហានិភ័យធំៗ | ៤៦.០៤៩.១៩៩ | ១៨៥.០២៥.៦៨២ | ៣០.០០៨.៦៩៩ | ១២១.១៩៥.១១៨ |
| មិនមែនជាហានិភ័យធំៗ | ២៨៣.៣២៦.៧៧៨ | ១.១៣៨.៤០៦.៩៩៣ | ៣០១.៩១៨.៤០៣ | ១.២១៨.៨៤៤.៥៩៣ |
| | ៣២៩.៣៧៥.៩៧៧ | ១.៣២៣.៤៣២.៦៧៥ | ៣៣១.៩២៧.១០២ | ១.៣៣៩.៩៨៩.៧១១ |

ហានិភ័យធំ ត្រូវបានកំណត់និយមន័យដោយធនាគារជាតិនៃកម្ពុជាថាជាហានិភ័យឥណទានទូទៅចំពោះ អ្នកទទួលផលជាឯកត្តជន ដែលមានចំនួនលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។ ហានិភ័យនេះគឺមានចំនួនខ្ពស់ជាងឥណទាន ឬកិច្ចសន្យាដែលនៅមិនទាន់ទូទាត់ និងឥណទានឬកិច្ចសន្យាដែលបាន អនុម័តរួច ។

## ៧. ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន - សុទ្ធ (ត)

### (ង) តាមទំនាក់ទំនង

| | ២០១៨ | | ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| សម្ព័ន្ធញាតិ | ៣.៨០២.៥៩៣ | ១៥.២៧៨.៨១៩ | ២.២២៤.៥៤៤ | ៨.៩៨០.៤៨៤ |
| មិនមែនសម្ព័ន្ធញាតិ | ៣២៥.៥៧៣.៣៨៤ | ១.៣០៨.១៥៣.៨៥៦ | ៣២៩.៧០២.៥៥៨ | ១.៣៣១.០០៩.២២៧ |
| | ៣២៩.៣៧៥.៩៧៧ | ១.៣២៣.៤៣២.៦៧៥ | ៣៣១.៩២៧.១០២ | ១.៣៣៩.៩៨៩.៧១១ |

### (ច) អត្រាការប្រាក់

ឥណទាន និងបុរេប្រទានផ្តល់ដល់អតិថិជន ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំ ដូចខាងក្រោម៖

| | ២០១៨ | ២០១៧ |
|---|---|---|
| ឥណទានផ្តល់ដល់សម្ព័ន្ធញាតិ | ៣.00%-១0.00% | ២.៧៥% ដល់ ៧.៥0% |
| ឥណទានផ្តល់ដល់អតិថិជនខាងក្រៅ | ៧.00% - ២៤.00% | ៧.៥0% ដល់ ២៤.00% |

### (ឆ) វិភាគផ្សេងៗ

សម្រាប់ការវិភាគផ្សេងៗ សូមមើលកំណត់សំគាល់ ៣០ ។

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

## ៨. ទ្រព្យ និងបរិក្ខារ

| **សម្ព័ន្ធធនាគារ**<br>**នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៨** | ទ្រព្យកំពុងបង្កើត<br>ដុល្លារអាមេរិក | ដីធ្លី<br>ដុល្លារអាមេរិក | អគារ<br>ដុល្លារអាមេរិក | ការកែលម្អអគារ<br>ដុល្លារអាមេរិក | បរិក្ខារការិយាល័យ<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | បរិក្ខារផ្នែកព័ត៌មានវិទ្យានិងកុំព្យូទ័រ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|---|
| **តម្លៃដើម** | | | | | | | | |
| នាថ្ងៃទី ១ខែមករាឆ្នាំ ២០១៨ | ១៦.៣៥៥.៩៦៥ | ៨.៤៥០.៥៧០ | ២.១៥៤.៥៧០ | ៥.៦៨៩.២៤១ | ២.៤៤១.៨៥៧ | ១.៤៩៦.២៣១ | ២.៤៨៣.៤៤៩ | ៣៩.០៧១.៨៨៣ |
| ការទិញបន្ថែម | ១០.៧៦០.៧៦៨ | ៨៨០.០០០ | ១២០.០០០ | ៣.៦៨៥ | ៣១.១៩៤ | ១១១.៩៦០ | ៤១.៧១២ | ១១.៩៤៩.៣១៩ |
